រិុំ - មារឌី
សាស្ត្រាចារ្យភាសាខ្មែរ

លោកញ៉ែកថែម នឹង លាងហាប់អាន
ពិនិត្យ នឹងកែសម្រួល

# អត្ថបទខជ្ជ

រឿង

# ក្រុងសុភមិត្រ

ថ្នាក់ទី២ និងទី១ ទំនើប

រវ.11

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨ - វិថីព្រះបាទសីហនុ ភ្នំពេញ

ន.ន.ជ៉ូ ៦៨-៣-៦៣-

# កម្មវិធីសិក្សាថ្នាក់ទី ២ និង ទី ១ ទំនើប

## រឿង

## ក្រពើសុំមិត្រ

808

អត្ថាធិប្បាយពន្យល់

ដោយ


អ៊ុំ-មារឡឺ

សាស្ត្រាចារ្យភាសាខ្មែរ


ក្រោមការពិនិត្យ និង ការណែនាំ

របស់


លោក ញ៉ុក-ថែម និង លោក លាង ហាប់ អាន

សាស្ត្រាចារ្យនៃមហាវិទ្យាល័យអក្សរសាស្ត្រ

និងវិទ្យាស្ថានជាតិគរុកោសល្យ



ផ្សាយចេញពី

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ លេខ ១៣៨ វិថីព្រះបាទសីហនុ

ភ្នំពេញ ឆ្នាំ ១៩៦៣

# អារម្ភកថា

សៀវភៅសិក្សា - អត្ថាធិប្បាយ - ពន្យល់ រឿងក្រុងសុភមិត្រនេះ ពុំមែនជាស្នាដៃយ៉ាងឯក ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំឡើយ គឺគ្រាន់តែជាយោបល់ក្នុងការផ្ដល់នូវគំនិតមួយ ដ៏ស្ទួចស្ដើងតែប៉ុណ្ណោះទេ ។ ព្រោះជាមានឧបសគ្គមករាំងរាខ្ទះ ៗ ក៏ដោយ ក៏ខ្ញុំខំពុះពារសិក្សាស្រាវជ្រាវប្រមែប្រមូលនូវឯកសារនិងមតិផ្សេង ៗ មកចងក្រងជា "សៀវភៅសិក្សា-អត្ថាធិប្បាយ-ពន្យល់,, នេះ ដើម្បីគ្រាន់តែជាជំនួយមតិ ឬ ស្មារតី, ដល់អស់លោកអ្នកនិងមិត្ត ឬចំពោះអ្នកសិក្សាកាម, មួយផ្នែកតែប៉ុណ្ណោះ ។

មួយវិញទៀតសៀវភៅនេះ គ្រាន់តែជាលទ្ធផលនៃការពិសោធន៍របស់ខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវអំពីអក្សរសិល្ប៍ជាតិ ។ ដូចនេះ ខ្ញុំពុំមែនជាអ្នកប្រាជ្ញ ឬជាអ្នកនិពន្ធអក្សរសិល្ប៍ឡើយ ។ ឯការខុសឆ្គង, ការបោទនឹងដោះស្រាយបញ្ហាសោតទៀត ក៏តែងតែមានខ្វះខាតនិងពុំសមរម្យខ្លះ ៗ ជាមិនខាន ។ តែខ្ញុំសង្ឃឹម

ហើយនឹងរង់ចាំជានិច្ចទទួលនូវការរិះគន់គ្រប់បែបគ្រប់យ៉ាង ក្នុងការផ្តល់នូវមតិខ្លះៗទៀត អំពីសំណាក់អស់លោកអ្នក-មិត្ត និងអំពីសំណាក់អស់លោកអ្នកកវីនិពន្ធអក្សរសិល្ប៍ទាំងឡាយផង ។

ព្រោះថាគោលបំណងធំបំផុតរបស់ខ្ញុំ គឺគ្មានអ្វីក្រៅអំពីការចង់លើកដំកើងតម្លៃនៃអក្សរសិល្ប៍ជាតិយើងនេះទេ ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ញ៉ុក-ថែម និងលោក លាង-ហាប់អាន ដែលបានចំណាយពេលដ៏ថ្លៃថ្លារបស់លោក និងមិនខ្លាចនឿយហត់ក្នុងការជួយផ្តល់នូវមតិខ្លះៗ និងជួយពិនិត្យកែនូវសៀវភៅនេះដោយត្រួសៗ ដើម្បីធ្វើឲ្យការអត្ថាធិប្បាយពន្យល់រឿងសុភមិត្រនេះ កាន់តែសមរម្យថែមទៀត ។

ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះលោកកេង-វ៉ាន់សាក់ អគ្គនាយកនៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដែលលោកបានបញ្ហាត់បង្រៀនខ្ញុំ

និងនិស្សិតសាស្ត្រាចារ្យខាងភាសាខ្មែរទូទៅ ដោយគ្មានសំចៃកម្លាំង ដើម្បីណែនាំយើងខ្ញុំឲ្យចេះឲ្យយល់នូវរបៀបសិក្សាស្រាវជ្រាវអត្ថបទនិមួយ ៗ ខាងផ្នែកអក្សរសិល្ប៍ខ្មែរ ។

អាស្រ័យហេតុនេះ ខ្ញុំជឿជាក់ថា ៖ អត្ថបទវិជ្ជា „រឿងក្រុងសុភមិត្រ„ នេះជាវិភាគទានមួយទៀត ដែលសម្រាប់ផ្តល់នូវមតិក្នុងការដោះស្រាយ និងជាពត៌មានខ្លះ ៗ ចំពោះអស់លោកអ្នកនិងមិត្ត ក្នុងការស្រាវជ្រាវផ្នែកអក្សរសិល្ប៍យើងនេះ ។

ភ្នំពេញ ថ្ងៃ ២០ កុម្ភៈ ១៩៦៣

អុំ - ម៉ារី

# សេចក្តីសង្កេតរបស់លោក

សាស្ត្រាចារ្យ លាង-ហាប់អាន

ក្រោយដែលបានពិនិត្យកែសម្រួលនូវពាក្យពេចន៍ ឃ្លាប្រយោគ និងរបៀបរៀងថែបផែនអត្ថបទក្នុងមាតិការបៀបថែបបទ ខ្ញុំយល់ថា : សៀវភៅរបស់លោកជាជំពូកនេះ ពិតជាសមរម្យច្រើន, ខាងបច្ចេកទេស ពន្យល់ អត្ថាធិប្បាយ ត្រូវទៅតាមវិធីសាស្ត្រ ពន្យល់អត្ថបទរឿង, និងទាំងខាងការបញ្ចេញគោលគំនិត មតិ និងយោបល់, ស្របទៅតាមបញ្ហាចោទ និងដោះស្រាយខាងអត្ថន័យ អត្ថរូប និងអត្ថរសនៃរឿងក្រុងសុភមិត្រនេះហើយ ។

ក្បួនជំនួយដែលរៀបរៀងដោយអ្នកមានការអប់រំជិតដល់មានសញ្ញាប័ត្រ និងបច្ចេកទេសត្រឹមត្រូវក្នុងមុខវិជ្ជាខាងភាសាខ្មែរដូចរូបលោកនេះ, ពិតជាផ្តល់នូវប្រយោជន៍ជាគំរូច្រើនចំ

ពោះអស់លោកសាស្ត្រាចារ្យ សិស្សានុសិស្ស ដែលស្រក
ស្រះទញក្នុងការសិក្សាអក្សរសិល្ប៍ជាតិជាប្រាកដ ។

ភ្នំពេញ ថ្ងៃទី ១៧ កុម្ភៈ ២៥០៥ / ១៩៦១

លាង ហាប់អាន

(សាស្ត្រាចារ្យខាងភាសាខ្មែរ)

# តារាងកែពាក្យខុស

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ១ | ទី ៨ | អក្សរសិល្ប | អក្សរសិល្ប៍ |
| ១៨ | — ៤ | ទ៌ព | ទ័ព |
| ១៩ | — ៤ | មត្តា | មេត្តា |
| — | — ៦ | សន្ស | សន្សំ |
| ២៩ | — ១៤ | ឃីញ | ឃើញ |
| ៣៣ | — ៩ | តក្កសីលា | តក្កសិលា |
| ៣៤ | — ៧ | បុស្សរថ | បុស្សរថ |
| — | — ៨ | ផ្សង ៗ | ផ្សេង ៗ |
| — | — ១២ | វេសន្តរ | វេស្សន្តរ |
| — | — ១៣ | បំពោះព្រះអង្គ | ព្រោះព្រះអង្គ – |
| ៣៦ | — ១ | ប្រទក្សណា | ប្រទក្សិណា |
| ៤០ | ៣ | តាមមតិបែបតទៅ | តាមមត់ពីរបែបតទៅ |
| ៤២ | — ៩ | ត៏ | ក៏ |

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ៤៨ | ទី ៦ | ក្ទន | ក្ទង |
| ៥៦ | – ៨ | ឧមារវិធី : | ឧបមានវិធី– |
| ៦០ | – ៥ | សម្ទេងធ់ពីកោះ | សម្ទេងដ៏ពីកោះ |
| ៦២ | ១០ | ប – ស . ទ្ទុហវិធី | ថ – សទ្ទេហវិធី |
| ៦៥ | – ៥ | វិសេសសិល្បរម្មណតួសេ | វិសេស សិល្បរម្មណសេ |
| – | – | ប្រសាទសិល្បរម្មណន្ត | សោកសិល្បរម្មណតួ |

# រឿងក្រុងសុភមិត្រ

## អត្ថន័យ
១

## និទានន័យ

### ក- ប្រភេទ នឹង ប្រភព

#### ១- ប្រភេទអត្ថបទ

រឿងក្រុងសុភមិត្រ គឺជារឿងទី ៩ ក្នុងរឿងបញ្ញាសជាតក ដែលជារឿង៥០ ជាតក៍ និយាយអំពីកំណើតពោធិសត្វក្នុងអតីតជាតិនានា (មានជារឿងសាស្ត្រាល្បែងក្តី ដូចជារឿង ព្រះសុធន សព្វសិទ្ធិ សុភមិត្រ វរវង្ស សុរវង្ស ។ ល ។ ជាដើម) ។

ពលនាអក្សរសិល្ប៍ផ្នែកនេះ បានផ្អែកទៅលើទ្រឹស្តីពុទ្ធនិយម ហើយកើតឡើងនៅសម័យក្រោយអង្គរ ។ ដែលហៅថាជាតក

នោះ គឺជាកម្រងនៃរឿងការរបស់ព្រះពុទ្ធ កាលពីអតីតជាតិ ហើយដែលបានសំដែងអំពីសកម្មភាពរបស់ព្រះអង្គ ខាងផ្លូវមនុស្សធម៌ សច្ចៈ សុចរិត យុត្តិធម៌ មានព្រះទ័យសប្បុរសចំពោះមនុស្សសត្វទូទៅ ។

ពិតមែនតែរឿងបញ្ញាសជាតកមានឥទ្ធិពលចេញមកអំពីពុទ្ធនិយមក៏ដោយ ក៏ប៉ុន្តែរឿងនេះក៏អាចទទួលនូវឥទ្ធិពលមនុស្សនិយម ឬព្រាហ្មណនិយមខ្លះ ៗ ដែរ ។

រឿងជាតកដែលឋិតនៅលើមូលដ្ឋានពុទ្ធនិយម តែងតែប្រកបទៅដោយរបៀបរៀបរឿងឡើង ៣ យ៉ាងគឺ ៖

១– សេចក្តីផ្តើមរឿង : ដំណាលពីអតីត. . . .

២ – ដំណើររឿង : សកម្មភាពផ្សេង ៗ . . .

៣ – សេចក្តីបញ្ចប់ដោយការសជាតិ . . .

**២– អ្នកនិពន្ធ :**

គួរឲ្យស្តាយជាពន់ពេក ដោយនៅពេលដែលយើង

សរសេរ ទំនងធ្វើសេចក្ដីអត្ថាធិប្បាយនៃរឿង យើងពុំបានដឹងច្បាស់នូវជីវប្រវត្តិរបស់អ្នកនិពន្ធ ។ តែយើងគ្រាន់តែដឹងថា រឿងសុភមិត្រនេះ លោកអ្នកឧកញ៉ា គោសាធិបតី "កោ" ជាចាងហ្វាងក្រុមព្រះឃ្លាំងមណីរ័ត្ន បានតែងដោយប្រែពីភាសាបាលី រៀបរៀងមកជាភាសាជាតិបែបកំណាព្យសាស្ត្រ ល្បែងក្នុង គ.ស. ១៧៩៨ ហើយមានចំនួន ៣ ខ្សែ ។ (រឿងនេះក្រុមពុម្ពសាសនបណ្ឌិត្យបានពិនិត្យបោះពុម្ពផ្សាយ) ។

៣- កាលបរិច្ឆេទ :

គឺជារឿងព្រេងដែលមានដំណាលមកពីបុរាណថា ៖ ព្រះសង្ឃនៅស្រុក ឈៀងម៉ៃ ១ អង្គបានចេះចាំហើយតែងជាមគធៈភាសា រួមទាំងអស់ ៥០ រឿង ក្នុង ព.ស. ២០០០ ដល់ ២២០០ ហៅថាគម្ពីរបញ្ញាសជាតក ហើយរឿងនេះមាននៅក្នុងប្រទេសខ្មែរ លាវ និងភូមាប៉ុណ្ណោះ ក្រៅពីនោះគ្មាន ។

គួរកត់សំគាល់ទៀតថា : លោកអ្នកស្រុកញ៉ាគោសាធិបតី „ គៅ " នៃរឿងក្រុងស៊ុកម៉ត្រនេះ ក្នុងរាជ្យព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ពី គ.ស. ១៧៩៦–១៨៣៤ ។ ព្រះរាជាអង្គនេះជាព្រះរាជបុត្រច្បងនៃព្រះបាទ អង្គ អេង ។

១– សង្គមដ្ឋាន :

ក– សង្គមប្រវត្តិ :

តាមកាលបរិច្ឆេទនៃរឿង (គ.ស. ១៧៩៨) យើងឃើញថា : រឿងក្រុងស៊ុកម៉ត្រសរសេរឡើង ក្នុងសម័យកាលនៃការគ្រប់គ្រងនៃព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ។ នៅពេលនោះ ព្រះរាជាអង្គនេះ ត្រូវបិតនៅក្រោមរាជានុសិទ្ធិរបស់លោក តេន ( Ten) ។ លុះព្រះជន្មបាន ១៤ ព្រះវស្សា គេក៏នាំព្រះរាជាអង្គនេះធ្វើរាជាភិសេកនៅឯបាងកក ក្រោមអធិបតីភាពនៃព្រះចៅសៀម ។

គឺនៅក្នុងបតវត្សនេះហើយ ដែលប្រទេសកម្ពុជា ត្រូវទទួល គ្រោះថ្នាក់ដោយចំបាំងរាំងជុលយ៉ាងធំ មានការកាប់សម្លាប់គ្នា ដោយសៀមនិងយួនបានចូលមកលុកលុយ ធ្វើចំបាំងដណ្តើម ទឹកដីរបស់ខ្មែរ ហើយមានការបែកបាក់សាមគ្គីរវាងខ្មែរនិងខ្មែរ ផង ។ អ្នកខ្លះចូលសៀម ខ្លះចូលយួនដើម្បីប្រឆាំងនឹងគ្នាឯង មានការក្បត់នឹងគ្នាឯងទៀតផង ។

ដូច្នេះឃើញថា: សម័យនោះប្រទេសយើងពុំបានមាន សភាពស្រួល សម្បូរ សប្បាយ ត្រជាក់ត្រជុំ មូលមិត្តគ្នានៅ ឡើយទេ ។

៦- សន្ធិសញ្ញា :

ដោយការកើតចលាចល មានចំបាំងរាំងជុលពីក្រៅប្រទេស និងរាំងក្នុងប្រទេស ដូច្នេះហើយដែលបង្កើតជាបញ្ហាចោទឡើង ចំពោះអ្នកកវីនិពន្ធរឿងនេះ ។ បានសេចក្តីថា : ដោយចង់ឲ្យ

សង្គ្រាមទាំងនោះរលាយលែងទៅវិញ ដើម្បីបង្កើតនូវសន្តិភាព ទើបលោកឧកញ៉ាគោសាធិបតី គៅ និពន្ធរឿងនេះឡើង ដើម្បីទុកជានិមិត្តរូបនៃសេចក្តីសង្ឃឹមរបស់លោក ។

៣- សន្តិមបរិយាកាស :

ដូចជាយើងបានពោលរួចមកហើយ សេចក្តីសង្ឃឹមក្នុងការបង្កើតនូវសន្តិភាព តែងតែបិតដុះជាប់នឹងអារម្មណ៍របស់លោកឧកញ៉ាគោសាធិបតី គៅ ជាដរាប ។

អាស្រ័យហេតុនេះ បានជាសេចក្តីសង្ឃឹមទាំងនោះដែលជាបរិយាកាសនៃមូលដ្ឋានបង្កើតនឹងណែនាំឲ្យលោកតែងនិពន្ធរឿងនេះឡើង ។

## រូបគ៌យ

១- តួអង្គ :

ក- ឈ្មោះ-មុខងារ :

---

| ល | នាមតួអង្គ | ឋានៈ | វង្សត្រកូលឋាន |
|---|---|---|---|
| ១ | ព្រះបាទក្រុងសុភមិត្រ | ចម្បាំងកត្តីវង្ស | ជាស្តេចសោយរាជ្យ |
| ២ | ព្រះនាងកេសនី | — | អគ្គមហេសីព្រះបាទសុភមិត្រ |
| ៣ | ជ័យសែន ជ័យទត្ត | — | ជាបុត្រព្រះបាទសុភមិត្រ នឹងព្រះនាងកេសនី |
| ៤ | ក្រុងអសុភមិត្រ | — | ជាអនុជព្រះបាទក្រុងសុភមិត្រ |
| ៥ | នាយព្រានមញ្ញា | — | ជាអ្នកថែរក្សាចៅជ័យសែន ជ័យទត្ត |
| ៦ | នាយភោគ្រាសាគរ ពាណិជ | — | អ្នករើសយកព្រះនាងកេសនី |

## ១– លក្ខណៈ

យើងអាចដឹងទំនងឃើញមកហើយនូវតួអង្គជារូប ដែលបិតនៅក្នុងរឿងនេះ តែបើយើងសង្កេតឲ្យបានច្បាស់លាស់បន្តិចទៀត យើងអាចឃើញនូវតួអង្គជាអរូបមួយទៀតដែលជាតួទំនាស់ទីងគ្នាយ៉ាងដាច់ណាត់ៗ គឺអំពើបាប នឹងអំពើបុណ្យៗ

តើគូទំនាស់នេះ មានឯកភាពដែរឬទេ? – យើងដឹងហើយថា ចាប់តាំងពីដើមនៃរឿងរហូតដល់ចប់ គូទំនាស់រវាងបាបនិងបុណ្យ ចេះតែធ្វើដំណើរប្រឆាំងគ្នាជានិច្ចឥតឈប់ឈរ លុះដល់ចប់រឿង ។ ដូច្នេះឃើញថា: គូទំនាស់រវាងបាបនិងបុណ្យនេះ មានឯកភាពដាច់ខាត ។

២– កាល-អាកាស :

ក– ទីកន្លែង :

រឿងក្រុងសុភមិត្រនេះ កើតមានឡើងនៅក្នុងនគរបម្យាកបុរីគ្ន - នៅក្នុងព្រៃ - នៅឆ្នេរសមុទ្រ និងនៅឯនគរតក្កសីលា ។

ខ– ពេលវេលា :

ពេលវេលានៃរឿងនេះ មានរយៈកាលវែងណាស់ ។ គឺចាប់តាំងពីព្រះបាទក្រុងសុភមិត្រត្រូវព្រះអនុជក្បត់ រហូតដល់ចប់ មួយជីវិតរបស់ព្រះអង្គ ។

៣ - វិភាគរឿង និងចលនា :

យើងអាចចែករឿងក្រុងសុភមិត្រនេះជា ៣ ចលនា៖

ក - ចលនាទី ១ : ការក្សត់នៃក្រុងសុភមិត្រ .

ទំព័រ ៣ . . . ទំព័រ ១៣ នៃវគ្គទី ១

« ពីរកាលកប្បខណ្ឌទាំង . . . គន្លឹកពន្លឺណោះ» ។

ខ - ចលនាទី ២ , ការព្រាត់ប្រាសនៃព្រះបាទ

ក្រុងសុភមិត្រ .

(ទំព័រ ១៣ ក្នុងវគ្គ ១ . . . ទំព័រ ១១ វគ្គ ២)

ក្នុងចលនានេះ យើងអាចចែកជាខណៈដូចតទៅ :

១ - ទំព័រ ១៣ . . . ដល់ទំព័រ ១៩ វគ្គ ១

ទុក្ខវេទនារបស់ព្រះបាទសុភមិត្រតាមផ្លូវ .

២ - ទំព័រ ១៩ . . . . ទំព័រ ២២ វគ្គ ១

ព្រះបាទសុភមិត្រនាំមហេសីឆ្លងសមុទ្រ .

៣ - ពីទំព័រ ២២ . . . . ដល់ទំព័រ ២៣ វគ្គ ១

ព្រានលួងលោមយកកុមារ (ជ័យសេន—ជ័យទត្ត) ទៅ.

៤–ពីទំព័រ ២៣ . . . .   ដល់ទំព័រ ៣០ ខ្សែ ១

ពាយកេក្រោសាគ ពាណិជរលោមខាងកេសរ៏.

៥–ពីទំព័រ ១ ខ្សែ ២ : . .   ដល់ទំព័រ ៨ ខ្សែ ២

សុភមិត្រស្វែងរកបុត្រនឹងមហេសីមិនឃើញ .

៦–ពីទំព័រ ៨ . . , ,   ដល់ទំព័រ ១១ ខ្សែ ២ .

ការពិតណាំភាគម្មជាតិ .

## *គ– ឋលនាទី ៣ : ការជួបជុំនៃក្សត្រទាំង ៤ អង្គ*

(ពីទំព័រ ១១ ខ្សែ ២ . . .   ដល់បប់) .

ក្នុងឋលនាទី ៣ នេះ យើងអាចចែកជាវណ្ណៈទៀត ៖

១–ទំព័រ ១១ ខ្សែ ២ . . .   ដល់ទំព័រ ២៣ ខ្សែ ២ .

ក្រុងសុភមិត្របានឡើងសោយរាជ្យនៅនគរតក្កសីលា ,

ក- ពិធីផ្សងបុស្សរថ,

១–ពិធីធ្វើសួតិចំរើនព្រះជន្មព្រះបាទក្រុងសុភមិត្រ.

២- ពីទំព័រ ២៣ . . .   ដល់ទំព័រ ២៦ ខ្សែ ២'

ព្រាហ្មណ៍មន្ត្រីនាំកុមារទៅថ្វាយក្រុងសុភមិត្រ,

៣–ពីទំព័រ ២៦ . . .   ដល់ទំព័រ ៨ ខ្សែ ៣,

កុមារទៅយាមសំពៅបានជួបមាតា·

ក–តាឃាភេត្រានាំភស្តុភារទៅថ្វាយព្រះបាទសុភមិត្រ.

ខ- ព្រះនាងកេសរីសោកាល័យដល់បុត្រនិងស្វាមី,

គ – កុមារនិយាយរៀបរាប់ពីការព្រាត់ប្រាស់មាតាបិតា,

៤– ពីទំព័រ ៨ . . . ដល់ទំព័រ ១៩ ខ្សែ ៣,

ព្រះបាទក្រុងសុភមិត្រឲ្យពេជ្ឈឃាតនាំកុមារទាំងពីរទៅសម្លាប់,

៥ – ពីទំព័រ ៨ . . . ដល់ទំព័រ ១៩ ខ្សែ ៣

ការជួបជុំនៃក្សត្រទាំង ៤ អង្គ.

ក– ការសាកសួរនឹងដឹងកុមារជាបុត្រ,

ខ– ព្រះបាទក្រុងសុភមិត្រយាងទៅរកនាងកេសរី,

៦– ពីទំព័រ ១៩ . . . ចប់,

អំពីការសជាតិ,

## ៣– តាមន័យ .

មុននឹងពោលហើយនឹងដោះស្រាយបញ្ហា គប្បីយើងធ្វើសេចក្តីសង្ខេបជាមុនសិន ៖

សេចក្តីសង្ខេប ៖

(តាមសៀវភៅព្រះពុទ្ធទំនាយ ដោយពុទ្ធឃោស ខបណ្ឌិត្យ)

ព្រះបាទ សុភមិត្រ សោយរាជ្យដោយយុត្តិធម៌នៅនគរ ចម្បានាគបុរីរដ្ឋ ជាមួយព្រះអគ្គមហេសីព្រះនាមនាង កេសរី ទ្រង់មានព្រះរាជបុត្រ ២ អង្គ ព្រះនាម ជ័យសែន ជាបង នឹង ជ័យទត្ត ជាប្អូន ។

ព្រះបាទ អសុភមិត្រ ជាព្រះអនុជ កាន់តំណែងជា មហាឧបរាជ ។ ដោយមានចិត្តទឹងប្រណែននឹងរាជសម្បត្តិ កើតចិត្តក្បត់ ហើយបានលើកទ័ពទៅឡោមព័ទ្ធមហាប្រាសាទ ដែលនាំឲ្យព្រះបាទក្រុងសុភមិត្រ ភៀសព្រះអង្គចេញចាក ពោលប្រាសាទជាមួយនឹងមហេសី ព្រមទាំងព្រះរាជបុត្រទៅគង់ នៅក្នុងព្រៃ ។

ព្រលឹងខ្មែរ

លុះមកដល់ឆ្នេរ នទី ក្រុងសុកមិត្រនឹងមហាសីទ្រង់គក់ស្លុតខ្លួនសោយសោកជាពន់ពេក ហើយទ្រង់សម្រេចចិត្តនាំមហាសីហែលឆ្លងទៅមុន ទុកបុត្រទាំងពីរនៅប្រចាំឆ្នេរសមុទ្រម្ខាង ។ ក្រោយដែលនាំមហាសីហែលឆ្លងទៅ មានព្រានមច្ឆាពីរនាក់ចែវទូកមកឃើញកុមារទាំងពីរ ក៏លោមចាប់យកទៅ ។

ដល់ត្រើយនាយ ក្រុងសុកមិត្រទុកមហាសី ហើយត្រឡប់មករកបុត្រវិញ ។ ពេលនោះមាននាយក្រោសាគរពាណិជ បើកសំពៅមកឃើញព្រះនាង គង់នៅតែម្នាក់ឯង កើតចិត្តប្រតិព័ទ្ធ ក៏ចាប់ដាក់សំពៅយកទៅ ។

ក្រុងសុកមិត្រ ត្រឡប់មកវិញរកបុត្រមិនឃើញ ទ្រង់សោយសោកសង្រេងសន្លប់បាត់ស្មារតី ។ លុះភ្ញាក់ពីសន្លប់វិញ ព្រះអង្គក៏ត្រឡប់ទៅរកមហាសីឯត្រើយម្ខាងវិញ ។ ទ្រង់រក

មហាសមិទ្ធិមិនឃើញទៀត ក៏ទ្រង់វិយោគលុះដល់សន្ធប់ ៗ លុះដឹងខ្លួនហើយ ក៏ធ្វើដំណើរតែឯកឯងត្រាច់ចរដោយឥតទិសៅ ។ គួរកត់សំគាល់ថា ៖ ការព្រាត់ប្រាសនេះ គឺបណ្ដាលមកអំពីកម្មផលរបស់ព្រះអង្គក្នុងអតីតជាតិ ដោយព្រះអង្គបានយកកូនសត្វសេកឲ្យព្រះរាជបុត្រលេងហើយកម្មពៀរវេរានេះឯង តាមទាក់ទិនព្រះអង្គអស់ ៥០០ ជាតិទើបរួច ។

ព្រះបាទក្រុងសុភមិត្រយាងទៅដល់នគរ តក្កសិលាហើយ តាប់ជួនព្រះមហាក្សត្រគ្រងនគរនោះទើបសោយទិវង្គតទៅ ពួកព្រាហ្មណ៍បុរោហិតបានធ្វើពិធីផ្សងបុណ្យរថ ដើម្បីគ្រប់គ្រងនគរ ។ ក្រុងសុភមិត្រត្រូវពលសេនាមុខមន្ត្រីយាងស្ដេចទៅសោយរាជ្យនៅនគរនោះ ។

ដំណាលអំពីព្រានមច្ឆា ដែលចង់យកកុមារទាំងពីរមានអនាគតប្រសើរ ក៏នាំយកទៅថ្វាយព្រះបាទក្រុងសុភមិត្រ ។ ពុំស្គាល់ជាបុត្រទេ ។ ប៉ុន្តែទ្រង់ទទួលថែរក្សា ហើយស្រឡាញ់

ជួបកូនបង្កើត ។ ចំណែកនាងកេសនីវិញ ត្រូវនាយគេត្រានាំទៅដល់នគរតក្កសីលានោះដែរ ហើយបានចូលទៅក្រាបបង្គំគាល់ព្រះបាទសុកមិត្រ ផងលាងនាយពាណិជ ។ ពេលនោះក៏បាត់ឲ្យកុមារទាំងពីរនៅចាំយាមសំពៅ ដែលជាហេតុនាំឲ្យកុមារជួបនាងកេសនីជាមាតា ។ ដោយបានជួបគ្នាម្ដាយនឹងកូនស្រវ៉ាឱបអោបឡោះអាល័យដោយក្ដីនឹករឭក ។

ចំណែកពួកគេត្រាទាំងឡាយ ក៏ចោទប្រកាន់ថា កុមារបានស្រឡាញ់ប្រពន្ធនាយសំពៅ ។ ដំណើរនេះបានជ្រាបដល់ទៅព្រះបាទក្រុងសុកមិត្រ ។ ក៏ប្រើឲ្យពេជ្ឈឃាតចាប់កុមារទាំងពីរយកទៅសម្លាប់ ។

ដោយការទូលទាស់របស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យ អំពីការយកកុមារទៅសម្លាប់ដោយឥតជំនុំរកហេតុផលជាមុនសិន , ក្រុងសុកមិត្រក៏ប្រើឲ្យអាមាត្យទៅតាមនាំយកកុមារមកវិញ ដើម្បី

សោកសៅ ៗ កុមារទាំងពីរទូលខ្លួនការព្រាត់ប្រាស់អំពីឪពុក ទូលនាមមាតាបិតា ៗ ប្រាប់ដូច្នេះ ក្រុងសុភមិត្រស្ទុះទៅឱបបុត្រទាំងពីរដោយក្ដីអាណិតអាសូរជាអនេក ៗ ក្រោយនោះព្រះបាទក្រុងសុភមិត្របានយាងទៅរកនាងកេសនីនៅឯសំពៅ ៗ

ក្សត្រទាំង ៤ សោយសោកជាខ្លាំង ៗ ទ្រង់ត្រឡប់មកប្រាសាទវិញ សោយរាជ្យជាសុខក្សេមក្សាន្តរហូតដល់ទិវង្គត ៗ

៤– មូលបញ្ហា ៖

រឿងក្រុងសុភមិត្រ ជារឿងមួយដែលបង្ហាញនូវកម្មពៀរវេរាពីអតីត ដែលមនុស្សត្រូវទទួលនូវកម្មផលនៅក្នុងបច្ចុប្បន្ន ៗ ជាពិសេសអ្នកនិពន្ធចង់បង្ហាញនូវតួទំនាស់រវាង បុណ្យ និង បាប នេះឯង ៗ បានសេចក្ដីថា ៖ កាលបើមានបញ្ហាកើតឡើងចំពោះតួអង្គណាហើយ តួអង្គនោះពុំអាចចៀសរួចផុតបានឡើយ គឺត្រូវតែទទួល ហើយជាពិសេស ពុំអាចបកបត

ប្រឆាំងទៅវិញទៅមកផង ។ គោលគំនិតនៅទៀតគឺ៖ សន្តិភាពនេះឯង ដែលអ្នកគីទិតទួបង់លើកយកមកលាតត្រដាងបង្ហាញក្នុងសម័យកាលនេះ ។

## ៣- បញ្ហាចោទ និង បញ្ហាដោះស្រាយ :

<u>គោលមតិសំខាន់ ១</u> : រឿងក្រុងសុភមិត្របិតនៅលើ៖

បលនាទី ១ : ការក្សត់នៃក្រុងអសុភមិត្រ

បលនាទី ២ : ការព្រាត់នៃក្រុងសុភមិត្រ

បលនាទី ៣ : ការជួបជុំនៃក្សត្រទាំង ៤ អង្គ ។

### បលនាទី ១

បញ្ហាចោទទី១: ហេតុអ្វីបានជាក្រុងអសុភមិត្រក្សត់?

ការដោះស្រាយ : មានប្រភពក្នុងហេតុ ២ យ៉ាងគឺ៖

ហេតុទី ១: គឺដោយសារបាបរបស់ក្រុងសុកមិត្រដែលបានធ្វើអំពីអតីតជាតិ ហើយមកផ្សាំទុកក្នុងជាតិនេះ ដែលបណ្ដាលឲ្យក្រុងអសុកមិត្រកើតចិត្តខឹងប្រណែននឹងព្រះវៀម ហើយបណ្ដាលឲ្យមានចិត្តក្បត់លើកទ័ពទៅឡោមវាំង ដើម្បីដណ្ដើមយករាជសម្បត្តិ ។

ហេតុទី ២: ក្នុងកាលដែលក្រុងអសុកមិត្រ កើតចិត្តក្បត់ចង់បានរាជសម្បត្តិនោះ បើយើងពិភាក្សាទៅតាមបញ្ហាមនុស្ស យើងអាចបញ្ជាក់បានថា បញ្ហាដែលមាននៅក្នុងលោកយសចុះ ទីងជាបញ្ហាទាក់ទងទៅនឹងបញ្ហាសង្គមមនុស្ស ។

ហេតុនេះ ក្រុងអសុកមិត្រក៏ដូចជាមនុស្សខ្លះទៀតទាំងអស់ដែរ តែងតែមានចិត្តលោភលន់ឥតឈប់ឈរ ។

បញ្ហាទី ២ — ហេតុអ្វីក៏ព្រះបាទក្រុងសុកមិត្រលះបង់រាជសម្បត្តិទុកឲ្យព្រះអនុជរបស់ព្រះអង្គគ្រប់គ្រងទៅវិញ ។

<u>ការដោះស្រាយ</u> – ចំពោះសំនួរនេះ យើងដោះស្រាយបាន ដូចតទៅ ៖

ក) បើតាមទស្សនពុទ្ធនិយម តួអង្គពោធិសត្វត្រូវតែប្រកបដោយ មេត្តាករុណា ធ្វើបុណ្យទាន ព្រមទាំងសុខចិត្តលះបង់ទ្រព្យសម្បត្តិ ប្រពន្ធកូន អាយុជីវិតរបស់ខ្លួនឯងផង ។ ធ្វើដូច្នេះ ដើម្បីសន្សំនូវសីលទាន ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធនៅថ្ងៃក្រោយ ។

១) ម្យ៉ាងទៀតដោយព្រះអង្គយល់ឃើញថា: ទ្រព្យសម្បត្តិ យសស័ក្តិទីងរូបសម្បត្តិរបស់យើងនេះ សុទ្ធតែជារបស់អនត្តា កើតមកហើយតែងតែវិនាសទៅវិញ ។

– ដោយយល់ឃើញថា: មានតែសីលទាន ទើបនាំឲ្យព្រះអង្គរួចពីសេចក្តីទុក្ខបាន ។ ដូចជាព្រះអង្គបានបញ្ជាក់នៅគន្ថវគ្គទី ១ ទំព័រ ១៣ ថា „ស្តេចគិតឃើញអនិច្ចា រូបអនត្តា ឥតខ្លឹមឥតសារសូន្យសោះ ។ សង្ខារបណ្តាលទោសស្មោះ

ឥតត្រើយឥតគោះ ពំនាក់ពំនឹងរូបបាន ។ យស់យល់តែស័ល ទឹងតាន ទៀងទើបនាំប្រាណ រូបចេញពីបក្កាយ" ។

អាស្រ័យហេតុនេះហើយ បានជាព្រះអង្គពុំព្រមប្រទុស្ត-កាយតបតនឹងប្អូនវិញ ហើយសុខចិត្តតែដើរចាកចេញពីនគរជាមួយនឹងភរិយាព្រមទាំងព្រះរាជបុត្រាទៅតាមកម្មផលរបស់ខ្លួន ។

បញ្ហាទី ៣ : ហេតុអ្វីបានជាព្រះបាទក្រុងសុកមិត្រមិន ច្បាំងតតាំងនឹងព្រះអនុជ ?

<u>ការដោះស្រាយ</u> យើងអាចបញ្ជាក់បានថា: ព្រះអង្គមិន ច្បាំងតទល់នឹងព្រះអនុជព្រោះ ៖

ក - បើតាមប្រភពរឿងវិញ គេបានបញ្ជាក់ឲ្យយើងឃើញថា : កាលបើព្រះអង្គច្បាំងតបតវិញទៅនាំឲ្យកើតមានមហន្តរាយឡើងក្នុងការធ្វើសង្គ្រាមនោះ គឺព្រះអង្គបារម្ភខ្លាចស្លាប់ដល់ប្រជារាស្ត្រទាំងនគរ ដោយសារតែការដណ្ដើមរាជ្យគ្នានេះ ។ ដូចព្រះអង្គបានបញ្ជាក់ក្នុងខ្សែ ១ ទំព័រ ១៣ ថា ៖

«បើយើងតតាំង កងទ័ពចេញច្បាំង ឱយយល់ឫទ្ធិ ក្រែងកើតកង្វល់ អម្ពល់លោចក្តី អស់ប្រាណ ក្រស្តផងទាំងឡាយ ។ នឹងកើតផ្សារក្តៅ ព្រាត់ប្រាស់កូនចៅ ហិនហោចខ្ចាត់ខ្ចាយ ស្លុតស្លាប់ស្បូវស្បៀ សោះ ហេតុនេះអញណាយ មិនឱយអន្តរាយ ដល់ជាតិឡើយហោង »

អាស្រ័យហេតុនេះ ទើបព្រះអង្គសម្រេចព្រះទ័យថា មិនច្បាំងតបវិញឡើយ គឺសុខចិត្តភៀសចាកចេញពីនគរ ចូលទៅនៅក្នុងព្រៃហេមពាន្តវិញ ដើម្បីរកសន្តិភាព ហើយត្រូវតាមគំនិតក្នុងពុទ្ធសាសនាថា «ពៀរមិនអាចរម្ងាប់បានដោយពៀរ» នេះឯង ។

## បញ្ហាចោទទី ៤: អំពីបញ្ហាគុណធម៌

ព្រះបាទក្រុងសុភមិត្រមិនច្បាំងនឹងព្រះអនុជ សុខព្រះទ័យលះបង់រាជសម្បត្តិ ព្រះរាជវាំង ព្រោះប្រាថ្នាដោះស្រាយរកសន្តិភាព នេះជាលក្ខណៈគុណធម៌ពោធិសត្វមួយផ្នែកដែរ ។

តែត្រូវយើងបញ្ជាក់ថា៖ គុណធម៌ក្រុងសុភមិត្រមិនមែនជាគុណធម៌

តំណាងសភាវៈល្អនោះទេ (មិនមែនដូចជាព្រះរាមក្នុងរឿងរាមកេរ្តិ៍ឡើយ) ។ ចំណែកតួអង្គក្រុងអសុកមិត្រ ដែលមានចិត្តក្បត់នឹងព្រះរៀមឯងដូច្នេះ គឺដោយសារអំពើបាបដែលក្រុងសុកមិត្របានធ្វើពីអតីតជាតិ ហើយដែលមកផ្តន្ទាក្នុងជាតិនេះ ។ យើងត្រូវដឹងថា: ក្រុងអសុកមិត្រ ក៏មិនមែនជាតួអង្គដំណាងសភាវៈអាក្រក់ដែរ ។

យោបល់រួមក្នុងផលជាធី ១ :

តាមការសង្កេតទូទៅក្នុងបលនាទី ១ នេះ យើងអាចបញ្ជាក់បានថា ការក្បត់របស់ក្រុងអសុកមិត្រនេះច្រើនតែពឹងផ្អែកទៅលើបញ្ហាកម្មផល របស់ព្រះបាទក្រុងសុកមិត្រតែប៉ុណ្ណោះ ។

X X
X

## បលនាទី ២

**<u>បញ្ហាទី ១</u>** : ហេតុអ្វីបានជាក្រុងសុកមិត្រត្រូវព្រាត់ប្រាស់មហេសីនិងបុត្រ ៗ

<u>ការដោះស្រាយ</u> : យើងអាចដោះស្រាយបានដូចតទៅនេះ ៖

– ដូចជាយើងបានបញ្ជាក់នៅក្នុងបលនាទី ១ រួចមកហើយ អំពីបញ្ហាដែលជាផលអាក្រក់នាំឲ្យក្រុងសុកមិត្ត ត្រូវវិនាសអំពីនគរ ត្រាច់ចរក្នុងព្រៃព្រឹក្សា ៗ

ជាពិសេស នៅក្នុងបលនាទី ២ នេះ ផលនៃអំពើបាប ដែលក្លាយមកជាពៀរវេរា ព្រេងវាសនា តាមផ្ដន្ទាទោសក្រុងសុកមិត្រ ហើយដែលក្រុងសុកមិត្រគ្មានសមត្ថភាពនឹងអាចគេចដោះខ្លួនឲ្យផុតពីទណ្ឌកម្មនេះបានឡើយ គឺកម្មពៀរវេរា ព្រេងវាសនា ដែលជាកម្លាំងមួយខ្លាំងក្លាបំផុត (Force fătâle) ហើយមកផ្ដន្ទាក្រុងសុកមិត្រ ៗ ត្រូវតែទទួលជាដាច់ខាត ៗ ដូច

ជាទៅខ្សែទី១ ទំព័រ ២១ បានបញ្ជាក់ថា៖ « កម្មឯងពីព្រេងខ្លួនហើយ ធ្វើម្ដេចស្ងួនគើយ ចៀសវាងពុំបាន » ដូច្នេះក្រុងសុកមត្រដែលត្រូវនិរាសពីនគរ ព្រាត់ប្រាស់ពីមហេសីនិងបុត្រ គឺដោយសារតែងទាស់វាសបុណ្យនិងបាប ដែលក្រុងសុកមត្របានកសាងពីអតីតជាតិ ។

បញ្ជាក់ :

ក- ការព្រាត់ប្រាស់ក្នុងពុទ្ធនិយម មិនដូចជាការព្រាត់ប្រាស់ក្នុងព្រាហ្មណ៍និយមឡើយ ។ គឺនៅក្នុងលទ្ធិព្រាហ្មណ៍និយម ការព្រាត់ប្រាស់កើតមកពីទំនាស់ ការប្រយុទ្ធដោយសការៈល្អ និងសការៈអាក្រក់ ។ ជាពិសេស ដោយការទាក់ទងទៅនឹងជីវភាពមនុស្សនេះឯង ដូចជាព្រះរាមត្រូវព្រាត់នាងសីតា គឺដោយសារការសង់សីតារបស់ក្រុងរាពណ៍ ។

១- ពិតមែនហើយតែរឿងនេះជារឿងពុទ្ធនិយម តែយើងឃើញថា: ការព្រាត់ប្រាសរបស់ព្រះអង្គព្រះពោធិសត្វនេះបានបញ្ជាក់ឲ្យមើលឃើញនូវសេចក្ដីទុក្ខព្រួយ សោកសង្រេងសង្រែ ដែលមានលក្ខណៈជាមនុស្សសុទ្ធ ៗ ដូចជា :

១)- ក្នុងពេលដែលក្រុងសុភមិត្រ ហៅលង្វង់សម្រុទ្រជាមួយនឹងព្រះនាងកេសរី ព្រះអង្គតែងតែនឹករឭកព្រះកជបុត្រទាំងពីរ ៗ ទ្រង់សោយសោកអាឡោះអាល័យយ៉ាងខ្លាំង ៗ

២)- នៅពេលដែលព្រះបាទក្រុងសុភមិត្រ ទ្រង់ឃ្លាតអំពីព្រះនាងកេសរី ហៅលត្រឡប់ទៅចម្លងព្រះកជបុត្រនោះ ព្រះអង្គទ្រង់សោយសោកនឹកយ៉ាងខ្លាំងទៅដល់នាងកេសរី ៗ

៣)  នៅពេលដែលនាយកេត្រា មកបង្ខំចាប់ព្រះនាងទៅ នាងកេសរី យំសោយសោកទឹកភ្នែកទៅដល់ព្រះស្វាមីនឹងព្រះរាជបុត្រទាំងពីរ ដែលនឹងយំរកម្ដាយ ដើម្បីតាមទៅ ។

បញ្ជាក់ក្នុងបញ្ហាចោទទី ១

ដោយសង្ខេបមកក្នុងបញ្ហាចោទទី ១ នេះទៅ យើងបានដឹងថា៖ ផ្នែកនេះជាផ្នែកមួយ បញ្ជាក់អំពីសេចក្ដីស្នេហារវាងឪពុកម្ដាយនឹងបុត្រធីតា តើមានកំរិតត្រឹមណា ? ។

បញ្ហាចោទទី ២– តើការដោះស្រាយទុក្ខឧបសគ្គ ទុក្ខព្រួយក្នុងចិត្តនិយម មានលក្ខណៈយ៉ាងណា ?

ការដោះស្រាយ :

តាមលទ្ធិចិត្តនិយម គួរតែពុំមានសមត្ថភាពនឹងដោះស្រាយ

អ្វីឡើយ ។ បើប្រសិនជាមានបញ្ហាវិបត្តិជាឧបសគ្គហោចឡើង ចំពោះតួអង្គ គឺបុណ្យនោះទេ ដែលមកជួយដោះស្រាយនូវឧបសគ្គទាំងនោះ គឺផលល្អដែលបានកសាងពីអតីតជាតិ ។

បើពុំនោះសោតទេ ទើងមានអន្តរាគមន៍នៃទេវៈទាំងឡាយ ដើម្បីជួយដោះស្រាយនូវវិបត្តិអ្វីមួយ ។ ។ តួអង្គទុកដូចជាគ្រឿងចក្រ ហើយដែលត្រូវកសនានោះទេ ដែលលើកទុកលើកដាក់ទៅតាមផលល្អនិងផលអាក្រក់ ។

<u>បញ្ជាក់ :</u> ការដោះស្រាយនូវឧបសគ្គ បញ្ហាស្មុគ្រស្មាញ ឬសេចក្ដីទុក្ខព្រួយក្នុងលទ្ធិពុទ្ធនិយម ពុំដូចជាការដោះស្រាយនៅក្នុងលទ្ធិព្រាហ្មណនិយមឡើយ ។ ព្រោះប្រសិនបើគេត្រូវការដោះស្រាយនូវវិបត្តិអ្វីមួយ ។ គេច្រើនជាដាច់ខាតយកបំប៉ាំងមកធ្វើជាធំ ។ បានសេចក្ដីថា ៖ មានតែសង្គ្រាមតែប៉ុណ្ណោះ ដែលអាចធ្វើឲ្យគេរកផ្លូវដើរទៅរួច ។ ឧទាហរណ៍ដូចជារឿងរាមកេរ្ដិ៍-រឿងទិព្វសង្វារ ឬរឿងមហាភារតជាដើម ។

បញ្ហាទី ៣ - ហេតុអ្វីបានជាក្រុងសុគម្រិត្រកបុត្រទីង មហេសីពុំឃើញ ?

កាដោះស្រាយ បានជាព្រះបាទក្រុងសុគម្រិត្រ រកបុត្រ ទីងមហេសីពុំឃើញព្រោះ ៖

– នៅក្នុងរឿងយើងឃើញថា : ក្រុងសុគម្រិត្របានត្រ-ឡប់មករកមហេសីពុំឃើញទ្រង់សោយសោកា, ក្រោយពីដីង ស្មារតីឡើងវិញ, ព្រះអង្គក៏ត្រឡប់ទៅរកមហេសីវិញ តែ ទ្រង់រកពុំឃើញទៀត ។ ក្រុងសុគម្រិត្រទ្រង់វិយោគលុះដល់ សន្ធប់ ។ ដឹងខ្លួនកាលណា ក៏ធ្វើដំណើរតទៅមុខទៀតដោយ ឥតទិសដៅ ។

– ការដែលព្រាត់ប្រាស់កាំយាទីងបុត្រនោះ គឺដោយ ពៀរវេរាផលអាក្រក់តាមមកផ្តន្ទា ហើយដែលក្រុងសុគម្រិត្រត្រូវ

តែទទួលផលផាប់ខាត ។ ដូចជានៅក្នុងខ្សែទី ២ ទំព័រទី ៦ អ្នកនិពន្ធបានបញ្ជាក់ថា ៖

«ព្រះអង្គវែងទុក្ខទល់ ហេតុអំពល់អំពើពៀរ
កាលស្ដេចយកបក្សី សត្វសេកសោមទុយបុត្រា ។
ទាំងពីរយកមកលេង ពិតពុំក្រែងពៀរវេរា
ហើយចោចភេមសារិកា បីទង់ទើបឈាមប្រាលផ្កា ។
យកកូនពីសម្បុក មេវាទុក្ខពេកក្ដាត់ក្ដៅ
ហើយយកទៅទុកនៅ ដែលគួចដើមពីមុនវៃ »

បណ្ណាល័យជាតិ

បានសេចក្ដីថា ៖ កាលស្ដេចយកបក្សីសត្វសេកសោមទុយបុត្រលេង ទាញទង់ប្លាបស្លាប ចេញឈាមប្រាលផ្កា ហើយក្រុងសុកមិត្រ បានយកសត្វនោះទៅទុកក្នុងសំបុកដូចដើមវិញ ។ គឺកម្មពៀរវេរានេះឯងដែលផ្ដល់ឲ្យផលអាក្រក់ទាំងទុយរកបុត្រនឹងមហេសីពុំឃើញ ។

តែបើយើងនិយាយអំពីនិពន្ធវិធីវិញ យើងឃើញថា:

ដើម្បីឲ្យរឿងក្រុងសុគមិត្រនេះទៅជារឿងកំសត់ ក្នុងលទ្ធិនិយម អ្នកនិពន្ធគេបានប្រើនូវកលសាស្ត្ររបស់គេក្នុងការនិពន្ធតែង ។ អាស្រ័យហេតុនេះ បានជាគេត្រូវឲ្យក្សត្រទាំង ៤ អង្គនេះព្រាត់ប្រាស់គ្នា ដើម្បីឲ្យស្របទៅតាមកម្មពៀរនៃរឿងទាំងមូលនេះផង ។

ម្ល៉ោះហើយការកំសត់ក៏កើតមានឡើង ដោយធ្វើឲ្យព្រះបាទក្រុងសុគមិត្ររកបុត្រ-រកមហេសីមិនឃើញ ។

បញ្ហាបណ្ដាប់បន្សំ — អំពីលក្ខណៈតួអង្គក្នុងចលនាទី ២

១– <u>ក្រុងសុគមិត្រ</u> :

–(ទំព័រ ១៣ ខ្សែ ៩) គ្រាន់តែឮថាព្រះអនុជក្សត់ ក្រុងសុគមិត្រទ្រង់ក្រោធ ក្ដៅថ្ងើម ស្ទើរបែកទ្រូង ហើយមាននេត្រាប្រហាលដូចអគ្គី ។

–(ទំព័រ ២០ ខ្សែ ១) មកដល់ឆ្នេរសមុទ្រមហានទី ក្រុង

សុគមិត្រគិតភ័យ ទ្រង់សោយសោកយ៉ាងខ្លាំង ។

— (ទំព័រ ២៤ វគ្គ ១) ដោយគាល័យបុត្រនិងមហេសី ក្រុងសុគមិត្រសោយសោកដល់សទូច ។

**សេចក្ដីបញ្ជាក់ :**

ការសោក, ការគិតភ័យទាំងអស់នេះ សុទ្ធតែជាលក្ខណៈនៃមនុស្សធម្មតា ។ ដែលមិនខុសពីរឿងព្រាហ្មណនិយម ដែលមានព្រះពមជាអាទិទេព ក៏គង់ប្រែទៅជាមនុស្សភាព នៅពេលខ្លះ ៗ ដែរ ។

ដូច្នេះ ទុកជារឿងព្រាហ្មណនិយមក៏ដោយ ពុទ្ធនិយមក៏ដោយ ក៏តួអង្គឯកពុំអាចស្ថិតនៅជាតួអង្គអច្ឆរិយៈរហូតដល់ចប់ដែរ ។ ព្រោះថា : រឿងទាំងនោះគឺជាតួអង្គរបស់មនុស្ស ដែលបិតនៅក្នុងសង្គមមនុស្ស បានប្រឌិតនិពន្ធតែងឡើង ។

**២— ជ័យទត្ត ជ័យសែន**

កុមារទាំងពីរនេះ គិតតែពីយំ ភ័យខ្លាច កាលបើឃើញព្រានមច្ឆាសាកសួរ ៗ មិនដូចជាបទុមវង្សកូនមរណមាតាសោះ ដែលមានបិតុក្លាហានដ៏មុះមុត ៗ បើនិយាយពីព្រះជន្មនៃកុមារទាំងពីរនេះវិញឃើញថា : មានព្រះជន្មស្មើគ្នាយ៉ាងពិតប្រាកដចំពោះកុមារជ័យសែន ៗ

## ៣- នាងកេសនី :

នាងកេសនី មានលក្ខណៈជាកន្យែសារពេជ្ឈ ដែលមានសេចក្តីស្មោះត្រង់ ស្វាមីភក្តិចំពោះស្វាមី ៗ នាងបានឆ្លើយតបទឹងនាយកេត្រាដោយវ៉ាតាចនគូន ហើយឆ្លើយប្រាប់តាមត្រង់ថា : នាងមានស្វាមីហើយ ៗ

ឃ្លាភ្ជាប់សេចក្តី — តាមការសង្កេតរបស់យើងក្នុង ចលនាទី ២ នេះ ឃើញថា : ការព្រាត់ប្រាសរបស់ក្សត្រទាំង ៤ នេះ គឺមកតែពីកម្មពៀរវេរាដែលបានបង្កពីអតីតជាតិតែប៉ុណ្ណោះ ៗ

តែយើងអាចចោទសួរថា តើការព្រាត់ប្រាស់នេះមានហេតុទេ ឬ? ត្រង់នេះយើងសូមពន្យល់នឹងអត្ថាធិប្បាយនៅក្នុងបលា ទី ៣ តទៅទៀត ។

x x x

## បលាទី ៣

បញ្ហាចោទទី ១– ហេតុអ្វីបានជាក្រុងសុតសោម បាន សោយរាជ្យនៅនគរតក្កសីលា?

**ការដោះស្រាយ :**

ដូចជាយើងបានបញ្ជាក់មកហើយថា : គឺ ដោយសារផលបុណ្យដែលទ្រង់កសាងអំពីជាតិមុន ទើបបានផ្តល់មកក្នុងជាតិនេះ ឲ្យទ្រង់បានសោយរាជ្យនៅនគរតក្កសីលានេះ ។ គឺ

ដោយសារព្រេងវាសនា ដែលក្រុងសុកមិត្រធ្វើដំណើរមកចំនគរ តក្កសីលា, ហើយដែលជាផលនៃអំពើល្អ បាននាំឲ្យអ្នកនគរនោះ ធ្វើពិធីផ្សងបុស្សរថមកយាងស្តេចឲ្យទៅគ្រងរាជ្យនៅនគរនោះ ។

យើងដឹងថា : ក្នុងការដែលក្រុងសុកមិត្រទទួលនូវរាជសម្បត្តិនេះ គឺមិនមែនដោយសារមធ្យោបាយ ការប៉ុនប៉ង ឬមានសមត្ថភាពក្នុងការតស៊ូអ្វីឡើយ (ដូចជារឿងមាយាស្រីជាដើម ដែលបេះប្រើមធ្យោបាយ នឹងប្រាជ្ញា ផ្សេង ៗ ដើម្បីជួយសង្គ្រោះជីវិតរបស់ខ្លួន) គឺដោយសារព្រះអង្គទទួលផលល្អអំពីជាតិមុន ហើយជាតិក្រោយនេះ ក្រុងសុកមិត្រត្រូវតែទទួល ទ. ខ្សែ ២ ទំព័រ ១៥ (ចាអស់នេះឯង) ត្រង់នេះគួរយើងធៀបប្រៀបទៅនឹងព្រះបាទវេស្សន្តរ ដែលស្តេចចេកក្រស្ត នៅមាតុលនគរ បានថ្វាយរាជសម្បត្តិចំពោះព្រះអង្គ មានព្រះទ័យជ្រះ

ថាទៅសាងព្រះផ្នួសឯភ្នំគិរីវង្កត ។

## បញ្ហាចោទទី ២– មតិនិយមក្នុងការផ្សងបុស្សរថ

**ការដោះស្រាយ :**

ដើម្បីជ្រើសរើសអ្នកមានបុណ្យ គេធ្វើពិធីផ្សងបុស្សរថ ហើយបើបុស្សរថនោះទៅឈប់ចំពោះមុខបុគ្គលណា គេសន្មត់ថាបុគ្គលនោះទុកជាអ្នកមានបុណ្យ ហើយត្រូវបានឡើងគ្រប់គ្រងនគរ ។ នេះបង្ហាញឲ្យឃើញថា : ទោះជារឿងក្រុងសុកមិត្រជារឿងពុទ្ធនិយមសុទ្ធសាធក៏ដោយ ក៏នៅតែមានបញ្ហាពាក់ព័ន្ធទៅនឹងប្រពៃណីទំនៀមទម្លាប់តាមលទ្ធិព្រាហ្មណ៍ដែរ ។ បានសេចក្តីថា : ដោយអ្នកករនិពន្ធរឿងនេះ ពុំទាន់ផ្តាច់ឲ្យជ្រះស្រឡះនៅឡើយ ពីឥទ្ធិពលព្រាហ្មណ៍និយម ដែលចូលមកលុកលុយកាលពីជំនាន់មហានគរ, សម័យនគរនឹងបុរីនគរនោះឯង ។

ក្នុងការប្រចក្សណា ៣ ដុំនោះគេ

- ប្រចក្សណាពីស្ដាំទៅឆ្វេង សម្រាប់សួស្ដីមង្គល

- -ដ- ពីឆ្វេងទៅស្ដាំ ចំពោះវត្ថុជាទីពុក

ការលះអាល័យ ។

បញ្ហាចោទទី ៣ ហេតុអ្វីបានជាក្រុងសុគមិត្រមិនស្គាល់បុត្រ ?

ការដោះស្រាយ : មូលហេតុដែលបណ្ដាលឲ្យក្រុងសុគមិត្រមិនស្គាល់បុត្រ មានដូចតទៅ ៖

មូលហេតុទី ១ – ដូចយើងបានបញ្ជាក់ក្នុងចលនាទី ១ ឬទី ២ រួចមកហើយ ការព្រាត់ប្រាស់ ការសោយទុក្ខវេទនា ៗលៗ របស់ក្រុងសុគមិត្រទឹងព្រះរាជវង្សនេះ គឺបណ្ដាលមកពីកម្មពៀរវេរារបស់ព្រះអង្គ ៗ ហេតុនេះដោយសារតែអំពើបាបទាំងនេះហើយ ដែលធ្វើឲ្យព្រះទ័យមានមិច្ឆាបថ ចំពោះ

ក្រុងសុកមិត្រដែលបណ្ដាលមិនឲ្យស្គាល់បុត្របានថែមទៀតៗ ដូចជាអ្នកនិពន្ធបានបញ្ជាក់ថា ៖ ទំព័រ ២៥ ក្នុងខ្សែ ២ :

„ហេតុបាបបាំងក្សត្រក្សាន ពីបុរា អាភព្វច្រើនគ្រា
នឹងឲ្យរងវេរា ជំរាបរៀងរាល់សព្វជាតិ ។
ស្ដេចភ្ញាំងភ្លេចពួងព័ណ៌ ពិតពុំស្គាល់បុត្រឯងអាទិ៍
ស្ដេចស្គាល់មានមារយាទ ផ្ដាច់បម្រើត្រូវព្រះទ័យ" ។

មូលហេតុទី ២ — តែបើតាមមតិនិយមក្នុងលោកិយនៅវិញ គេពោលថា ហេតុដែលបណ្ដាលឲ្យក្រុងសុកមិត្រមិនស្គាល់កូននេះ ដោយមកពីព្រះអង្គព្រាត់យូរពេក គឺរហូតដល់ទៅជាង ៧ ឆ្នាំ ។ ម្ល៉ោះហើយអាចឲ្យព្រះអង្គពុំចាំមុខបានឡើយ ។ ព្រោះតាមធម្មតាក្មេង (សិក្សាតាមចិត្តសាស្ត្រ) តែងតែឆាប់ផ្លាស់ណាស់ ព្រោះនៅវ័យដែលកំពុងត្រូវការទទួលនូវសេចក្ដីរីកធាត់ធំ ដកកំពស់ជូរបេះផង ។

មូលហេតុទី ៣ — ដោយការព្រាត់ប្រាស់យូរមកហើយផង ហើយគាប់ជួនជាព្រានទូលទៀតថា : ជាបុត្ររបស់ខ្លួន នោះព្រះអង្គ ក៏ពុំមានព្រះទ័យចាប់អារម្មណ៍ដល់រឿងរបស់ព្រះអង្គបន្តិចឡើយ ។

ត្រង់នេះហើយដែលធ្វើឲ្យព្រះអង្គពុំអាចស្គាល់ ជ័យសែន-ជ័យទត្ត ដែលព្រានយកទៅថ្វាយនោះថាជាបុត្ររបស់ព្រះអង្គបានឡើយ ។

បញ្ហាចោទទី ៤ — ហេតុអ្វីបានជាព្រះនាង កេសរី ស្គាល់កុមារទាំងពីរជាបុត្រ ?

<u>ការដោះស្រាយ :</u> យើងដឹងថា ក្នុងគ្រានោះព្រះបាទក្រុងសុកមិត្រ បានធ្វើពិធីជប់លៀងមួយដល់នាយគេត្រាទាំងឡាយ ដែលបានរើសព្រះនាងកេសរី ហើយដែលបានយកនូវផ្កាយផ្សេង ៗ ទៅថ្វាយព្រះអង្គដើម្បីជាកិត្តិយស ។

ដោយពុំមាននរណាជាទីទំនុកទុកព្រះទ័យ ព្រះអង្គក៏ចាត់មហាត្លឹកទាំងពីរគឺ ៖ ចៅជ័យសែន និង ជ័យទត្ត ឲ្យទៅចាំយាមសំពៅរបស់នាយកេត្រាទាំងនោះ ។ ទេសកាលត្វីដែលនាំឲ្យកុមារទាំងពីរនេះ ទៅចាំយាមចំសំពៅដែលនាងកេសនីនៅក្នុងទីនោះ ជាពិសេសទៅទៀត គឺនៅក្នុងកាលរាត្រីនោះព្រះនាងកេសនី បានសោយសោកថ្ងូររៀបរាប់ស្រណោះដល់បុត្រនិងព្រះស្វាមី ដែលនាំឲ្យជ័យសែនជាបងឮនូវទំនួញនោះហើយដាស់ជ័យទត្តជាប្អូន ដើម្បីនិយាយអំពីការព្រាត់ប្រាស់ពីមាតាបិតាដែរ ។ កុមារបានពោលឈ្មោះនគរបម្យាកបូរី, ឈ្មោះមាតាកេសនី, បិតាក្រុងសុភមិត្រ ដែលនាំឲ្យព្រះនាងកេសនីស្គាល់ជាក់ថាជារាជបុត្ររបស់ព្រះនាងពិតប្រាកដ ។

បញ្ហាចោទទី៥ – ការចោទប្រកាន់របស់ពួកកេត្រាចំពោះកុមារ។ ថា : កុមារនេះស្រឡាញ់

ប្រពន្ធនាយកេត្រា ដែលជាម្ដាយឯងនោះ

តើសមហេតុសមផលឬទេ ?

ការដោះស្រាយ ៖ យើងដោះស្រាយតាមមតិបែបគេទៅនេះ ៖

មតិទី ១ បើតាមលទ្ធិ ឬ ទ្រឹស្ដីពុទ្ធនិយម ការពោលប្រកាន់របស់នាយកេត្រាចំពោះកុមារនេះសមហេតុសមផលណាស់ ព្រោះក្នុងលទ្ធិនេះ ត្បូកនៃសារពេជ្រមិនអាចក្លាយទៅជាចាស់ផងឡើយ ។ បានសេចក្ដីថា: បើនៅក្រមុំ គឺនៅតែក្រមុំរហូតហើយមានរូបឆោមល្អថែមទៀត ។ ហេតុនេះហើយបានជាពួកកេត្រាមានការភ័ន្តច្រឡំបាន ដោយកុមារនេះធំផង ហើយមើលទៅព្រះនាងកេសទីក៏នៅក្មេងដែរ ។ ម្ល៉ោះហើយក៏ពោលថា កុមារនេះស្រឡាញ់នាងកេសទីទៅ ។ ដូចជារឿងហង្សយន្តជាកស្តុតាងស្រាប់ ។ ព្រោះថា: ចៅក្រំស្នា មិនព្រមស្រឡាញ់នារី ឬបុត្រីស្ដេចណាសោះ ។ ដល់ទៅ

ឃើញនាង បទុមកេសរ ដែលជាមាតារបស់ឯង ក៏មានចាប់ចិត្ត ស្រឡាញ់ភ្លាម ៗ ចុះបើបទុមកេសរមានវ័យចាស់ជរាវិញ ប្រហែលជាចៅក្រឹស្នាមិនទៅបេតីមោត្តើឡើយ ។

បើតាមមតិរបស់លោក ញ៉ុក-ថែម វិញលោកបានបញ្ជាក់ថា ៖ ទោះជាតួអង្គកន្យៃសារពេជ្រក៏ដោយ គង់តែប្រែប្រួលដូចជាមនុស្សធម្មតាដែរ ព្រោះថាមនុស្សគ្រប់រូបសុទ្ធតែ អនិច្ចំ ទុក្ខំ អនត្តា ៗ តែលោកបានបញ្ជាក់ទៀតថា : មានតែនាងវិសាខា ១ ប៉ុណ្ណោះទេ ដែលពុំមានប្រែប្រួលនូវវ័យ រូប ឬសោភ័ណឡើយ ៗ ក្រៅពីនោះទៀត មានតែទេវធីតា ទេវបុត្រដែលមិនប្តូរនូវរូប វ័យ ដែរ ៗ

– លោកបានបញ្ជាក់ទៀត ចំពោះរឿងហង្សយន្តថា ៖ រឿងនេះពុំពេញជាលក្ខណៈពុទ្ធនិយមឡើយ ៗ

រួមយោបល់ទៅ ៖ តាមមតិខ្ញុំយល់ឃើញថា : អ្នកនី

ខិតខំរៀនសូត្រមិនគ្រាន់ដោយ ឬរៀនហាត់រួយខ្លួនក៏ដោយ ប្រហែល ជានឹងឃើញនូវរូបសោភ័ណមិនប្រែប្រួល របស់នាងវិសាខានេះ ហើយបានជាលើកយកតួអង្គកនៃស្រាវពេជ្រ នៅឲ្យមានរូប សោភ័ណមិនប្រែប្រួលដូចជានាងនោះដែរ ។

មតិទី ២— តែបើយើងដោះស្រាយតាមបែបទេវនិយម ឬលោកិយនិយមវិញ យើងឃើញថា: ការនៅឲ្យប្រកាន់ពួក គេគ្រានេះពុំសមហេតុសមផលសោះ ។ ព្រោះធម្មតា ម្ដាយ ដែលបង្កើតកូនមកហើយ តែងតែមានវ័យច្រើនលើស យ៉ាង ហោចណាស់ត្រឹមបីតំណដែរ ។ មិនគួរណាឡើយពួក គេគ្រាតាំងនេះក៏ទប្រែឡំបានសោះ ។ ហើយម្យ៉ាងទៀតនៅ វ័យសែនជាបងនឹងទើបតែមានអាយុប្រហែលជាង ១០ ឆ្នាំសោះ ។ ហេតុនេះ តើយើងអាចនៅឲ្យថា ស្នាមានសេចក្ដីស្នេហាចំពោះ

ព្រះនាងកេសនី (ឬតាមមតិនិយមនៃពួកកេត្រា) ថាជាប្រពន្ធរបស់នាយកេត្រាបានដែរ ?

— តែគេអាចឆ្លើយវិញថា : ដោយនៅពេលនោះជាពេលរាត្រីដែលពុំអាចឲ្យយើងឃើញច្បាស់ ។ ម៉្លោះហើយពួកកម្មករទាំងនោះស្មានថាកុមារនេះ ទៅស្រឡាញ់ចាប់ឱបប្រពន្ធនាយកេត្រាមែន ។

ការចោទទឹងដោះស្រាយរបស់គេនេះក៏ត្រូវម្យ៉ាងដែរ ។ តែយើងចោទសួរគេទៀតថា : នៅពេលរាត្រីចុះ ជាពុំអាចដឹងច្បាស់, ចុះដល់ភ្លឺហើយម្ដេចក៏មិនវិនិច្ឆ័យមើលលក្ខណ មើលឫកពារ មើលមាឌរបស់គ្នា ដោយប្រៀបធៀបទៅព្រះនាងកេសនីផង - តែគេថា : ទេ ! នៅពេលដែលស្ដេចឲ្យយកទៅសម្លាប់នោះ គឺនៅពេលយប់ដែរ ។ បើគេឆ្លើយក៏ត្រូវដែរ តែនៅពេលដែលព្រាហ្មណ៍ សូមព្រះបាទក្រុងសុកមិត្រឲ្យទុក

ជំនុំជំរះនោះ ហើយដែលនៅចំពោះព្រះភ័ក្ត្រផ្ទាល់របស់ព្រះបាទក្រុងសុភមិត្រ – គួរណាស់តែព្រះអង្គក៏ដោយ ឬអស់មុខមន្ត្រីទូទៅក៏ដោយ ក៏គប្បីបេះគិតពិចារណាបន្តិចហើយ ទុកជាព្រះបាទក្រុងសុភមិត្រ ពុំទាន់សួរនូវរឿងហេតុរបស់កុមារទាំងពីរនេះក៏ដោយ ៗ តែផ្ទុយទៅវិញ លើកលែងតែព្រាហ្មណ៍បុរោហិតតែម្នាក់ប៉ុណ្ណោះ សុទ្ធតែជឿថាកុមារនេះ បានទៅស្រឡាញ់ប្រពន្ធនាយកេត្រាមែន ។

ត្រង់បញ្ហាទី ២ នេះ យើងឃើញថាការចោទប្រកាន់នេះពុំសម ហេតុសមផលសោះ ។

បញ្ហាចោទទី៦ – ហេតុអ្វីបានជាព្រះបាទក្រុងសុភមិត្រ ប្រើពេជ្ឈឃាតឲ្យយកកុមារ ទៅសម្លាប់ ?

ការដោះស្រាយ : ត្រង់បញ្ហាចោទសួរនេះ យើងអាច

ដោះស្រាយបាន ២ ខ ដូចតទៅ ៖

១– បានជាព្រះបាទក្រុងសុភមិត្រប្រព្រឹត្តចំពោះកុមារដូច្នេះ ព្រោះតាមធម្មតា ខ្លួនជាស្ដេចផែនដី កាលបើការពារនូវសេចក្ដីអសន្តិសុខចំពោះកៀរពុំបាន នោះគេទុកជាស្ដេចគ្មានសមត្ថភាពគ្រប់គ្រងនគររបស់ខ្លួន ។ ម្ល៉ោះហើយដើម្បីការពារកិត្តិយសទាំងអស់នោះ មានតែប្រើពេជ្ឈឃាដឲ្យយកកុមារទាំងពីរនេះទៅសម្លាប់ចោល ដើម្បីសងឲ្យសមតាមការប្រព្រឹត្តរបស់កុមារទាំងពីរដែលនាំអាប់កិត្តិយសដល់ព្រះអង្គ ។

២– តែបើដោះស្រាយ តាមមនុស្សនិយមវិញ ឃើញថា: ការបង្គាប់ឲ្យពេជ្ឈឃាដយកកុមារទាំងពីរទៅសម្លាប់នេះ ដោយហេតុតែព្រះបាទក្រុងសុភមិត្រខ្វះនូវការពិចារណា ខ្វះ

វិចារណញ្ញាណ ហើយជាពិសេសទៅទៀត បញ្ហានេះយើងឲ្យឃើញថា : គឺដោយសារព្រះបាទសុកមិត្រមានព្រះទ័យមោហៈខ្លាំងពេកទៅហើយ ជាពិសេស ដោយព្រះអង្គចង់ការពារទូកិត្តិយសរបស់ព្រះអង្គផង ទើបព្រះអង្គប្រើអំណាចឲ្យសមទៅតាមកំហុសទាំងនោះ ។ សេចក្តីតទ្បល់នឹងការណែនាំរបស់ព្រាហ្មណ៍ទេ ទើបព្រះអង្គសព្វព្រះទ័យឲ្យយកកុមារនោះមកសួរកេហេតុផល ឲ្យសមទៅតាមលទ្ធិប្រជាធិបតេយ្យវិញ ។

បញ្ហាចោទទី ៧ – ហេតុដូចម្តេចបានជាព្រះបាទក្រុងសុកមិត្រ ស្គាល់កុមារទាំងពីរ ថាជាបុត្របង្កើត ?

ការដោះស្រាយ :

ត្រង់នេះយើងអាចឆ្លើយបានភ្លាមថា បានជាព្រះបាទក្រុង

សុកមិត្រស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកុមារនេះបានប្រាប់ឈ្មោះនគរដែលមាតាបិតារបស់ខ្លួនសោយរាជ្យ, ប្រាប់ព្រះនាមមាតាបិតា ៗ ម្ល៉ោះហើយដោយសារពត៌មានទាំងនេះ ព្រះអង្គជ្រាបថា ចៅជ័យសែន និងជ័យទត្ត គឺជាបុត្ររបស់ព្រះអង្គ ៗ

តែគេចោទសួរទៀតថា ៖ហេតុអ្វីបានជាកុមារទាំងពីរនេះទៅប្រាប់ឈ្មោះនគរនិងព្រះវរមាតាបិតាដូច្នោះ យើងអាចឆ្លើយបានថា ៖

— ព្រោះកុមារទាំងពីរខ្លាចស្លាប់ ៗ គេសួរទៀតថា: ចុះហេតុអ្វីបានជាកុមារទាំងពីរខ្លាចស្លាប់ ? មកដល់បញ្ហាចោទសួរត្រង់នេះ យើងដូចជាពិបាកឆ្លើយបន្តិច ៗ តែឲ្យស្របទៅតាមដំណើររឿង យើងសូមដោះស្រាយដូចតទៅនេះ ៖

— ហេតុដែលនាំឲ្យព្រះបាទគ្រុងសុកមិត្រ ស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកាលពីជាតិមុនព្រះអង្គបានយកកូន

សេកមកបោចកោយស្វាបលេង ៗ តែដល់ក្រោយមកទ្រង់ក៏យក ទៅដាក់ក្នុងសំបុកដើមវិញ ៗ ដូចជាអ្នកនិពន្ធបានពោលបញ្ជាក់ ក្នុងខ្សែ ៤ ត្រង់ទំព័រ ២ ថា ៖

យកកូនពីសម្បុក    មេជាទុក្ខពេកក្ដាត់ក្ដៅ
ហើយយកទៅទុកនៅ    ដែលគ្លិចដើមពីមុនវៃ ។

ដូច្នេះហើយ បានជាកូនជាតិនេះពៀរវេរតាមផ្ដន្ទាធ្វើឲ្យ ក្រុងសុកមិត្រព្រាត់ប្រាស់គ្នាសិន ហើយដល់អស់កម្មពៀរ ក៏ តម្រូវឲ្យព្រះអង្គបានជួបបុត្រនឹងភរិយារបស់ព្រះអង្គវិញ ៗ បាន សេចក្ដីថា ការជួបបុត្រក្ដី ការជួបព្រះអគ្គមហេសីក្ដី គឺមកតែ ពីកម្មពៀរវេរអស់ជីវិតទៅ ហើយផលបុណ្យក៏បានមកសន្និត វិញតែប៉ុណ្ណោះឯង ។

### បញ្ហាចោទទី៨ - បញ្ហាតួអង្គ (ព្រះបាទក្រុង សុកមិត្រ)

ការដោះស្រាយ :

១- ក្នុងការព្រាត់ប្រាសពីនគរ, ពីបុត្រនឹងមហេសី ព្រះបាទក្រុងសុភមិត្រទ្រង់យំអាល័យបុត្រភរិយា ។ តែដល់ព្រះអង្គបានឡើងសោយរាជ្យនៅនគរតក្កសិលា ព្រះអង្គពុំមានព្រះទ័យនឹករឭកនឹងរកមធ្យោបាយណា ដើម្បីទៅរកមហេសីនិងបុត្ររបស់ព្រះអង្គឡើយ ។ ត្រង់នេះបញ្ជាក់ឲ្យឃើញថាក្រុងសុភមិត្រមានលក្ខណៈដូចជាមនុស្សធម្មតា ។ គឺនៅពេលណាមានទុក្ខព្រួយមកដល់ ក៏នឹកប្រពន្ធកូន តែដល់បានសប្បាយស្រណុកសុខស្រួល ភ្លេចអស់នូវសេចក្តីវេទនា ការកំសត់តាំងពីមុនៗ ហើយជាពិសេសភ្លេចដល់ទៅបុត្រនិងភរិយារបស់ខ្លួនទៀត ។ មតិអ្នកខ្លះបានពោលថា បានជាព្រះបាទក្រុងសុភមិត្របំភ្លេចអស់នូវបុត្រនិងភរិយាដូច្នេះ ព្រោះ ព្រះអង្គបានឡើងសោយរាជ្យ ហើយ ថែមទាំងមានស្នំឆ្វេង-ស្តាំ យ៉ាង

គកកុញទៀត ។ ការប្តូរពីពោធិសត្វភាពទៅជាមនុស្សភាពវិញនេះ ហើយដែលយើងចាត់ទុកតួអង្គនេះចូលទៅក្នុងពួកអ្នកអមនុស្សធម៌បានដោយសារហេតុសមផលជាពន់ពេក ។ តែបើតាមមតិរបស់លោក ញ៉ុក ថែម វិញ លោកបានបញ្ជាក់ថាត្រង់បញ្ហានេះ អ្នកកវីនិពន្ធបង្ហាញកម្មផលរបស់តួអង្គនុយកាន់តែច្បាស់លាស់ឡើងថែមទៀតតែប៉ុណ្ណោះ ។

២- បើយើងក្រឡេកមើលទៅក្នុងខ្សែទី ៣ វិញយើងរឹតតែឃើញច្បាស់ទៀតថា : ក្រុងសុភមិត្រមានលក្ខណៈផ្ទុយស្រឡះពីតួអង្គពោធិសត្វ ព្រោះគ្រាន់តែនាយកេត្រាខ្វល់ថា : កុមារអាំងពីបានប្រព្រឹត្តខុស ដោយបោចថាទៅលបលួចស្រឡាញ់ប្រពន្ធរបស់ខ្លួន ទ្រង់ក៏ប្រើពេជ្ឈឃាដចាប់ចងយកទៅសម្លាប់ភ្លាមដោយឥតបានគិតរិះពិចារណា វិនិច្ឆ័យស៊ើបអង្កេតឡើយ. បើពោលឲ្យខ្លីទៅទៀត ការប្តូរពីពោធិសត្វភាពទៅជាមនុស្ស

ភាពតែប៉ុណ្ណោះពុំមានគ្រប់គ្រាន់នៅឡើយ ។ ព្រោះថា ៖ ព្រះបាទគ្រុឌសុកម៌ត្រធ្លាក់ខ្លួនអន់ជាងមនុស្សធម្មតាទៅទៀត ។ ដូចជាព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ ខ្សែ ៧៧-៧៨-៧៩ ទំព័រ ៨០ ផង ។ ដែលពុំមានលក្ខណៈជាព្រះអាទិទេពភាព ឬជាមនុស្សភាពបន្តិចឡើយ ។

## បញ្ហាចោទទី ៤ – បញ្ហាសជាតិ.

ការដោះស្រាយ :

រឿងគ្រុឌសុកម៌ត្រ គឺជារឿងដែលគេបញ្ចូលទៅក្នុងពួករឿងជាតក ។ បានជាថាដូច្នេះ ព្រោះថា ៖ រឿងនេះដោះស្រាយតែពីបញ្ហាកម្មផល ហើយបើមានវិបត្តិអ្វីម្យ៉ាង ៗ កើតឡើងចំពោះតួអង្គ ក៏យកតែកម្មផលពៀរវេរាមកដាក់ពីមុខជានិច្ច ។

ម្យ៉ាងទៀត កូនរៀនជាតកនិមួយ ៗ នៅចុងក្រោយបំផុត គេតែងតែមានការសជាតិ គឺតួអង្គសំខាន់ ៗ ស្លាប់ទៅ ហើយនឹងកើតប្រកបដោយលក្ខណៈ នឹងគុណសម្បត្តិ គុណវិបត្តិតាមកម្មផលនៃការកសាង ៗ

ឯការសជាតិនៅកូនរៀនក្រុងសុកមិត្រនេះមាន ៈ

១- ក្រុងសុកមិត្រ —> ព្រះពុទ្ធអង្គ

២- នាងកេសនី —> ពិម្ពា

៣- ជ័យសែន —> រាហុល

៤- ជ័យទត្ត —> មហាអានន្ទ

៥- អសុកមិត្រ —> ទេវទត្ត ។

<u>សេចក្ដីញ្ញាក់បញ្ចប់ :</u>

កូនរៀនជាតកនិមួយ ៗតែងតែមាន ៈ

១- ផ្តើមរឿង = ដំណាលពីអតីតជាតិនៃអង្គពោធិសត្វ ។

២- ដំណើររឿង= អត្ថាធិប្បាយអំពីពោធិសត្វ ទាំងសាង

សីលទាន ។ ល ។

៣- ការសេជាតិ = លទ្ធផលនៃការខំសន្សំបានបារមី ។

X X X

## អត្ថរូប

### ក- បកាសរូប :

• ប្រភេទរូប :

ជារឿងបែបសាស្ត្រាល្បែង (គឺប្រលោមលោកបុរាណ) តែងជាពាក្យកាព្យផ្សេងៗ មានបទកាកគតិ·ព្រហ្មគីតិ·ភុជង្គលីលា·ពំនោល ជាដើម ។

២- អាស័យរូប

រឿងក្រុងសុភមិត្រនេះ បង្ហាញនូវកម្មផលផ្សេងៗដែលតួអង្គបានធ្វើពីអតីតជាតិ ហើយក្នុងបច្ចុប្បន្ននេះកម្មផលពៀរវេរាកាំងនោះមកផ្តន្ទាទោសសងជំនួសវិញ ។

៣– ប្រធានរូប –

ការផ្សងព្រេង និងការបណ្តាក់សនារបស់ព្រះបាទក្រុងសុភមិត្រនិងវង្សត្រកូល ឲ្យទៅតាមកម្មពៀរវេរា ដែលពោរពេញទៅដោយការកំសត់ព្រាត់ប្រាស់និកសទទៃ ៗ ។

១– បការរូប :

• – វចនរូប –

នៅក្នុងការតែងនិពន្ធនេះ អ្នកនិពន្ធបានប្រើពាក្យ :

– តែងកាព្យឆន្ទបែបបាលី

ទំព័រ ១ វគ្គ ១២ : «អញចាំអកី . . . . ទុកគសាសនា»

- ប្រើពាក្យបាលី: ព្រះវរបិតាមាតា . អត្ថ ។ ល ។

- ប្រើពាក្យសំស្រ្កឹតក្លាយ: ក្សត្រី ក្សត្រា ។

២- រចនារូប :

ក- ឃ្លាប្រយោគ :

ទោះជាឃ្លាបាលី ឬសំក្រឹតជាកាព្យក៏ដោយ ក៏អ្នកនិពន្ធបានរៀបរៀងឡើងមានចុងចួនត្រឹមត្រូវ តាមបែបបទវេយ្យាករណ៍ដែរ ។

ឧទាហរណ៍ កន្លែង ៤ ទំព័រ ១ ៖

“នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ គុណគុណំ . . .

. . . . សវ៌ធម្មោ គុណាករោ កបាលិនំ”

៣- រូបារម្មណ៍ ៖

ពិតមែនតែអ្នកនិពន្ធតែងរឿងនេះជាពាក្យកាព្យក៏ដោយ ក៏

ប៉ុន្តែលោកពុំគួចនូវរូបារម្មណ៍ខ្លះ ៗ ដែលជាសិល្បវិធីមួយដ៏ធ្វើឲ្យរឿងតាំងមូលមានចលនា, មានសោភ័ណភាពឡើងដែរ ដូចជា ៖

- និមិត្តរូបារម្មណ៍ – ឧទាហរណ៍ :

ក្នុងខ្សែ ២ ទំព័រ ៨ ៖

"ស្តេចថាខ្ញុំឮសព្ទសត្វ យំស្រងាត់ក្នុងព្រឹក្សព្រៃ
សែនសោយសោកអាល័យ អាឡោះលន់ពន់ពេកក្តាត់"

- ឧបមាវិធី :

ឧទាហរណ៍ = ទំព័រ ១០ ខ្សែ ២ ៖

"ឱសត្វសឹងព្រាត់ប្រាស់ឈ្មោលញី ដូចមេប្អូនស្រីប្រែប្រាស់ពីបង"

បានសេចក្តីថា ៖ កាលដែលក្រុងសុគមិត្រព្រាត់ប្រពន្ធកូនទៅ ព្រះអង្គត្រាច់ចរវគ្គតែម្នាក់ឯងក្នុងព្រៃដ៏ស្ងាត់ជ្រងំ ៗ នៅពេលនោះហើយ ដែលព្រះអង្គបានទតឃើញនូវធម្មជាតិ

ទាំងឡាយ មានចលនារស់រវើក តែមានបក្សាបក្សីខ្វះព្រាត់ ឈ្មោលញី ដូចជាព្រះអង្គព្រាត់មហេសីនិងបុត្រដែរ ។

គ - និពន្ធរូប :

១ - ការម្ករូប :

គេផ្ដើមរឿងដោយបទនមស្សការព្រះរតនត្រៃ ប្រាប់ឈ្មោះអ្នកនិពន្ធ និងប្រាប់ប្រភពនៃកំណើតរឿង ។

២ - វណ្ណនារូប :

ក - ការបង្ហាញតួអង្គដោយអ្នកនិពន្ធ ៖

ឧទាហរណ៍ = ក្នុងខ្សែ១ទំព័រ ១.

„កើតកាលកប្បខណ្ឌទាំង . . , មានទេវតាពេកកន្លង„

ខ - ការបង្ហាញរៀបរាប់អំពីប្រាសាទ ៖

ក្នុងការពិពណ៌នាអំពីប្រាសាទ អ្នកនិពន្ធរៀបរាប់ដោយ

ខ្លួនឯងអំពីបន្ទាយប្រាំពីរជាន់អំពីប្រាសាទស៏ដែតឆាយ ដោយមានក្បូរក្បាច់រចនាដ៏វិចិត្រ ៗ មានចំនួនរូបចម្លាក់ផ្សេង ៗ ជាច្រើនទៀតផង ។

ក្នុងការធ្វើពិពណ៌នានេះ អ្នកនិពន្ធបានបេះយកពាក្យពេចន៍ ជួនអក្សរផ្ទួប ៗ គ្នា សម្ដីប្រហែល ៗ គ្នា យកមកពិពណ៌នា ហើយដែលជាហេតុនាំឲ្យកើតរូបារម្មណ៍ឡើង ។

ឧទាហរណ៍ : ក្នុងខ្សែ ១ ទំព័រ ៥. . . , ៨

បន្ទាយប្រាំពីរជាន់ សិលាសរសើរព្រះបារមី

## គ– ការបង្ហាញរូបពលនាលើកទ័ពធ្វើចំបាំង –

ចំណែកក្នុងការពិពណ៌នារៀបរាប់អំពីការលើកទ័ពនេះ អ្នកនិពន្ធបានប្រើបទពំនោល ដែលសមទៅតាមបែបបទកំណាព្យ ព្រមទាំងមានរបៀបរៀបរយអំពីបេនា ៗ អ្នកនិពន្ធបានប្រើ

នូវវចនរូបវិធី បញ្ជាក់អំពីរូបករិយល ទាំងពួកពលសេនា ដែលនាំឲ្យយើងឃើញហាក់ដូចជានៅទីងៃក្កកស្ទុះ ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ១ ទំព័រ ១២ :

ក្ងូរៀបគដិសាកទ្ធុន ស្ទើរភ្លូកប្លូរិភជិល្អោះ

ឃ– ការពិពណ៌នាអំពីធម្មជាតិ –

នៅក្នុងខ្សែទី ២ អ្នកនិពន្ធបានបញ្ចូលអំពីការពិពណ៌នាធម្មជាតិទូទៅទាំងអស់ដែលមានបំនៅក្នុងព្រៃព្រឹក្ស ៗ អ្នកនិពន្ធរើសយកដើមឈើណាដែលមានអក្សរដូចគ្នា សម្ទង់ប្រហែលគ្នា យកមកដាក់ជិត ៗ គ្នា ធ្វើឲ្យកើតជាកំណាព្យឡើង ដែលមានការចាប់ចុងចួនពីរោះណាំគ្នា ជាទីចាប់អារម្មណ៍ក្រៃលែង ។

ក្នុងការរៀបរាប់អំពីធម្មជាតិនេះ អ្នកនិពន្ធបានរៀបរាប់ដោយវគ្គ ៗ ឬដោយពួក ៗ ដូចជា :

- ការរៀបចំពីដើមឈើ.
- ការរៀបចំអំពីសត្វម្រឹគ.
- ការរៀបចំអំពីសត្វស្លាប.

– ក្នុងការរៀបចំអំពីដើមឈើ អ្នកនិពន្ធប្រមូលឈ្មោះឈើធំ ៗ ដាក់តម្រៀបគ្នា លាយជាមួយសម្លេងពីរោះរណ្ដំធ្វើឲ្យមានបរិយាកាសកាន់តែរីករាយឡើង ៗ

– ក្នុងការរៀបចំអំពីសត្វម្រឹគ ឬសត្វស្លាបវិញ អ្នកនិពន្ធធ្វើឲ្យមានចលនារស់រវើក ហាក់ដូចកន្លែងនោះមាននៃរនៃរ ៗ

<u>យោបល់បញ្ចប់</u> – ការពិពណ៌នាធម្មជាតិរបៀបនេះជាការប្រពៃហើយប្រសើរហើយ តែបើតាមរបៀបនិពន្ធសាស្ត្រនៃរឿងនេះទៅវិញ ឃើញថាមិនសូវសមសោះ ហើយអ្នកនិពន្ធសោតទៀត ក៏ហាក់ដូចជាពុំបានបេះស្លាក់នូវបញ្ហាកទេសទាន

និពន្ធរូបវិធីច្បាស់លាស់ដែរ ព្រោះការរៀបរាប់នេះ មានការប្របូកប្របល់គ្នាដោយអន្ទើ ៗ ។ ឧទាហរណ៍ ដូចជាសត្វព្រៃនៅលាយជាមួយសត្វស្រុក — ឈើព្រៃលាយជាមួយឈើស្រុក ។ល។ ជាដើម ។ តែបើគ្រាន់តែស្សូរសព្ទសម្លេងនោះ ៗ ពិតជាពីរោះមែន ។

គ—នាដ្យវិធី

យើងឃើញថា ក្នុងបលនាទី ១ នាដ្យភាពបានកើតឡើង ដោយមានទំនាស់រវាងក្រុមសុភមិត្រ នឹងក្រុមអសុភមិត្រ គឺដោយសារបាបនេះឯង ដែលនាំឲ្យមានការទំនាស់រវាងក្សត្រទាំងពីរ គឺព្រះបាទក្រុងសុភមិត្រដែលទ្រង់ធ្វើបារមីដោយសារបុណ្យ ដល់ទ្រង់ត្រូវវិនាសបោលព្រះនគរទៅ គឺដោយសារតែបាបមានកម្មពៀរវេរាតែប៉ុណ្ណោះ ។

ដូច្នេះ គឺទំនាស់រវាងបាបនឹងបុណ្យនេះហើយ ដែលនាំឲ្យមានបលនានាដ្យភាពនេះឡើង ។

– ចំណោកនៅក្នុងបលនាទី ២ វិញ មានចំនាស់រាំងបុណ្យទឹងបាបនេះ បានឡើងកំរិតកាន់តែតឹងឡើង ៗ យើងឃើញថា នាដ្យសន្និវេសដែលនាំឲ្យយើងចង់ដឹងខ្លាំងឡើង ៗ អំពីក្រុងសុគមិត្រថា ៖

– តើកេមហេសី - បុត្រ ឃើញប្តីទេ ?

នាដ្យខណៈនោះ គឺ

– ក្រុងសុគមិត្រនាំមហេសីឆ្លងសមុទ្រទទឹង -

– ព្រានលួងលោមកុមារទាំងពីរ ៗ

– នាយកេត្រាលួងលោមព្រះនាងកេសនី ៗ

ប – សង្ខេបហៈរឹត.

យើងឃើញបលនាទំនាស់រាំងផលល្អទឹងផល ការគ្រក់ទៅមានកំរិតខ្លាំងដែល ៗ ប៉ុន្តែបរិយាកាសបានធូរស្រាលបន្តិចដោយផលល្អបាននាំឲ្យក្រុងសុគមិត្រ បានឡើងសោយរាជ្យ

ទៅនគរតក្កសិលា ។ ដែលនាំឲ្យយើងចង់ដឹងថា : តើព្រះអង្គបានជួបបុត្រភរិយាឬទេ ? តទៅទៀត សន្ទេហវិធីនេះ ក៏មានកំរិតខ្លាំងឡើងទៅទៀត ដែលនាំឲ្យយើងបែកជា ៖

១– សន្ទេហវិធីកើតឡើងដោយកើតមកអំពីទាន្យខណៈ:

– ព្រាននយកកុមារទៅថ្វាយក្រុងសុគមិត្រ ដែលនាំឲ្យយើងចង់ដឹងថា : តើក្រុងសុគមិត្រស្គាល់បុត្រឬទេ ?

– នាយគេត្រានាំនាងកេសរីទៅដល់នគរតក្កសិលា តើជួបនឹងព្រះបាទក្រុងសុគមិត្រឬទេ ?

– ព្រះបាទក្រុងសុគមិត្រឲ្យយកកុមារទាំងពីរ ទៅសំឡាប់ តើស្លាប់ឬទេ ?

២– សន្ទេហវិធីដែលកើតមកអំពីការចង់ដឹង-សង្ស័យ :

– តើក្រុងសុគមិត្របានជួបនឹងមហេសីឬទេ ?

— ក្រុងសុគមិត្រធ្វើទោសនាយកេត្រាប្លូ ។

៣– អត្ថរូប :

ក្នុងរឿងនេះ អ្នកនិពន្ធគេបានបញ្ចប់ដោយការជួបជុំនៃក្សត្រទាំង ៤ អង្គ និងការសដាតិនូវតួអង្គសំខាន់ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ៣ ទំព័រ ១៩, ខ្សែ ២ ទំព័រ ២០-២១ ។

X X X

## អត្ថរស
១

ក– បច្ចេករស : បច្ចេកសិល្បារម្មណរស ឬ តម្លៃសំខាន់ដែលឋិតនៅលើកាព្យសិល្បារម្មណ៍ ( Le poétique) ដែលថ្លែងរៀបរាប់អំពីដំណើររឿង ហើយជាពិសេស នៅពេលដែលអ្នកនិពន្ធពិពណ៌នារៀបរាប់ (Description) អំពី

ប្រាសាទទានាដែលប្រកបដោយពាក្យពេចន៍ទំនងកាព្យដ៏ពីរោះ ។

ឧទាហរណ៍ នៅវគ្គ ១ ចំពោះ ១-២-៣-៤-៥-៦-៧-៨-៩ និង ១០ ។

## ១- វិសេសរស :

វិសេសសិល្បកម្មណាត្តរស ឋិតនៅលើប្រសាទសិល្បកម្មណាត្តដែលមាន ៖

១ នាដ្យភាព (Le dramatique)

គឺកើតឡើងដោយនាដ្យវិធីផ្សេង ៗ មាននាដ្យសន្និវេស (Situation dramatique) ជាដើម ។

ឧទាហរណ៍ : គឺដោយសារចំនាស់ រវាងបុណ្យទឹកជាបនេះ ហើយដែលនាំឱ្យមានឧបសគ្គគឹងគែងឡើង ។ ត្រង់នេះយើងឃើញថាមាននាដ្យសន្និវេស ដែលនាំឱ្យយើងចង់ដឹងខ្លាំង អំពីព្រះបាទក្រុងតរុណភិត្រប៉ា : តើរកឃើញកូនប្រពន្ធឬទេ ?

នាដ្យខណៈគឺ :

១- ព្រានល្បួងលោមកុមារទាំងពីរ ។

២— ពាយភេត្រាល្បួងលោមមហេសី

- បលនាំគ្នាសរភេនដល់ល្អទីនគរក្រក ទៅ ដកតែខ្ញុំង ជផែប ។ តែបរិយាកាសបានផ្លាស់ប្តូរទៅវិញ ដោយព្រះបាទក្រុងសុគមិត្របានឡើងសោយរាជ្យនៅនគរតក្កសិលា ។ ហើយដែលនាំឲ្យយើងដឹងថា : តើទ្រង់បានជួបនឹងមហេសីឬទេ ?

- ព្រានយកកុមារទៅថ្វាយក្រុងសុគមិត្រ ដែលនាំឲ្យយើងចោទសួរថា : តើព្រះបាទក្រុងសុគមិត្រស្គាល់រាជបុត្រឬទេ ?

- នាដ្យសង្គីតមានកំរិតខ្លាំងដោយដំណើររឿងឋិតនៅលើមិច្ឆាបទ (erreur).

ឧទាហរណ៍ ព្រះបាទក្រុងសុគមិត្រឃើញបុត្រ ហើយ តែស្មានថាជាបុត្ររបស់ព្រានទៅវិញ ។

ព្រះអង្គស្មានខុសទៀតថាៈ កុមារទាំងពីរទៅស្រឡាញ់ប្រពន្ធនាយភេត្រាមែន ម្ល៉ោះហើយក៏ប្រើឱយពេជ្ឈឃាតយកទៅសម្លាប់ ។

២- កាំសត់ (le pyrrhique)

— កំសត់នេះលេចចេញពីនាដ្យភាព គឺទំនាស់រវាងព្រះបាទក្រុងសុកមិត្រ និងអសុកមិត្រ ។ បានសេចក្ដីថាៈ គឺរវាងបាបនិងបុណ្យដែលសុកមិត្រធ្លាប់សោយរាជ្យក្សេមក្សាន្តជាមួយនឹងមហេសីនិងបុត្រ (ដោយសារបុណ្យរបស់ព្រះអង្គ) ស្រាប់តែត្រូវព្រាត់ប្រាសទឹកសពីកជសម្បត្តិ គឺប្រាសាទ (ដោយសារអសុកមិត្រក្បត់ ) គឺដោយសារបាបរបស់ព្រះអង្គពីជាតិមុន ហើយជាតិនេះត្រូវតែទទួល ។

— ដោយព្រះបាទក្រុងសុកមិត្រត្រូវព្រាត់ប្រាសបុត្រភរិយា ។

— ដោយព្រះបាទក្រុងសុកមិត្រនាំមហេសីឆ្លងសមុទ្រ ។

កុមារយំសោកភេក្រះផខក ឆន៍ នាងកេសរិយំសោក

ព្រះស្វាមី–កេតុបុត្រ មុននាយកេត្រាចាប់យកនាងទៅ ។ កំសត់មកពីការព្រាត់ប្រាស់គ្នាជាយូរមកហើយ ។ បានជួបគ្នាវិញ ។

## គ- សព្វរស :

សព្វសិល្បរម្មរសថិតនៅលើ ៖

១– សោភ័ណ (Le beau) គឺល្អ ៖

– គុណផ្នែកអត្ថន័យដែលបង្ហាញនូវហេតុផល នៃអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តហើយ កម្មនោះវាវិលមកផ្ដន្ទាវិញជាពិសេសទៅទៀត គឺបង្ហាញឲ្យឃើញថា : ការគិតតែពីអត្ត ហើយផ្ដល់នូវទុក្ខវេទនាដល់មនុស្សខ្លួនទៅ នោះឃើញថា ពុំប្រសើរឡើយ ។ ដូចជាព្រះបាទក្រុងសុភមិត្រ នៅពេលដែលព្រះអនុជក្បត់ ព្រះអង្គពុំច្បាំងតបឡើយ ដោយខ្លាចប្រជារាស្ត្ររបស់ព្រះអង្គស្លាប់ មានទុក្ខព្រួយលំបាក ។ល។

ជាដើម ដោយសារតែខ្លួនដណ្ដើមរាជសម្បត្តិគេទៅវិញ ។

– ក្នុងផ្នែកអត្តរូប (វិធីនេះមានរបៀបពាក្យពេចន៍ជួនរណ្ដំ ផ្សំដោយសិល្បវិធីផ្សេង ៗ ។

២– អច្ឆរិយៈ (Le merveilleux)

ការហែលឆ្លងនៃសមុទ្រទទី ដែលធ្វើឲ្យយើងជឿពុំបានទាល់សោះ ព្រោះការហែលឆ្លងទៅវិញទៅមកនេះ ហាក់ដូចជាព្រែកមួយដែលមានទំហំសមគួរដល់មនុស្ស ។

៣– លោកិយសច្ចៈ (Le rêel)

ពិតមែនតែរឿងក្រុងសុភមិត្រនេះ ជារឿងពុទ្ធនិយមក៏ដោយ ក៏គំនិតនិពន្ធបានធ្វើឲ្យលក្ខណៈរបស់តួអង្គពោធិសត្វក្លាយទៅជាលក្ខណៈរបស់មនុស្សពិត ។ ក្នុងការរស់នៅក្នុងសង្គមមនុស្ស ។

ឧទាហរណ៍ : ការទឹងប្រទែងនឹងក្រុមអសុរមិត្រដែលមានចិត្តក្បត់ ការយំសោកអាណោះអាល័យពីលំបុត្រភរិយាដែលព្រាត់ប្រាស់ទៅ ។ ការយល់ខុសក្នុងមនុស្សម្នាក់, ក្នុងរឿងយកបុត្រខ្លួនទៅសម្លាប់ ។

– ការក្បត់របស់ក្រុមអសុរមិត្រ ជាបញ្ហារបស់មនុស្សដែលអាចកើតមានឡើងក្នុងការលោភលន់លន់សោយរាជ្យ ហើយដែលអាចមានរវាងបងប្អូនដូច្នេះ ។

មានបញ្ហាទំនៀមទម្លាប់ មានពិធីផ្សងបុស្សរថ ពិធីសូត្រចម្រើនព្រះជន្ម ជាដើម ដែលជាពិធីមានពិតប្រាកដក្នុងសង្គមមនុស្ស ។

– បញ្ហាដែលស្តេចតូចតាច ត្រូវតែចុះចូលនាំសួយសារអាករមកថ្វាយស្តេចចក្រពត្រាធិរាជ ។

– នោះជាចំណែកនៃរឿងក៏មានចំណុចខ្លះ ៗ នៅក្នុងសង្គមមនុស្សលោក ។ ឧទាហរណ៍ : ចិត្តភាពស្រុកទេស ឈ្មោះគគរ ។ល។

# និដ្ឋានកថា

ពិតមែនតែរឿងក្រុងសុភមិត្តនេះជារឿងរបស់ព្រះសង្ឃ នៅស្រុកឈៀងម៉ៃ ដឹកនាំបញ្ចូលមកក្នុងស្រុកទេសយើង ក៏ អ្នកកវីនិពន្ធយើងប៉ិនប្រសប់ណាស់ ដោយយករឿងនោះមក និពន្ធតែងឡើងឲ្យសមទៅតាមលក្ខណៈនៃរឿង បែបប្រទេស ជាតិ ទាំងឲ្យសមទៅតាមយុគ្គណៈនៃរឿងជាគកធង់ ដែល ធ្វើឲ្យអ្នកស្រុក អ្នកអាន ទស្សនា ហើយជាពិសេសចំពោះ ពុទ្ធសាសនិក មានចិត្តជាប់អារម្មណ៍ជាតទ់តេក ៗ

- ចប់ -

# ប្រធាន

១- ចូរអ្នកសិក្សាអំពីលក្ខណៈដែលបញ្ជាក់ថា រឿងក្រុងសុភមិត្រជារឿងអក្សរសិល្ប៍មួយពេញលក្ខណៈ ។

២- ទ្រឹស្តីព្រះពុទ្ធសាសនា បានចែងថា «ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់» ចុះហេតុដូចម្តេចបានជាព្រះបាទសុភមិត្រដែលបានប្រព្រឹត្តតែអំពើល្អក្នុងបច្ចុប្បន្នជាតិ ត្រូវបានទទួលលទ្ធផលផ្ទុយទៅវិញ

ចូរអ្នកសិក្សាវែកញែកឲ្យយោបល់ ?

៣- ចូរប្រៀបធៀបកំសត់ក្នុងរឿងក្រុងសុភមិត្រ និងក្នុងរឿងទុំទាវ ។

៤- ចូរស្រង់យកអត្ថបទកំណាព្យមួយ ក្នុងរឿងក្រុងសុភមិត្រដែលអ្នកយល់ថា អ្នកនិពន្ធសរសេរល្អ ហើយថែមទាំងមានសារៈសំខាន់ទៅតាមសាច់រឿងថែមទៀតផង ។

៥– អ្នកខ្លះពោលថា: ព្រះបាទក្រុងសុកមិត្រជាអត្តទត្ថបុគ្គល ព្រោះនៅពេលដែលអសុកមិត្រជាប្អូនដណ្ដើមរាជសម្បត្តិនោះ ព្រះអង្គបានកៀសចេញពីព្រះនគរជាមួយនឹងព្រះញាតិវង្ស ទុកឲ្យរាស្ត្ររស់នៅលំបាកវេទនា ក្រោមការជិះជាន់នៃក្រុងអសុកមិត្រ ។ (ចំពោះអ្នក តើយល់ដូចម្ដេចវិញ ?)

៦– ថា: «ឱប្អូនអើយ វាកៀរព្រងយើង ឯងដល់ហើយ ព្រលឹងបងអើយ កុំសោយសោកា„ ខ្សែ ១ ទំព័រ ៦ ។

ដោយសំអាងលើពាក្យលួងលោមរបស់ព្រះបាទក្រុងសុកមិត្រនេះ សូមអ្នកដោះស្រាយអំពីបញ្ហាកម្មផលក្នុងរឿងក្រុងសុកមិត្រ ។

៧– ពន្យល់អំពីកម្មពៀរក្នុងក្រុងសុកមិត្រ ទាំងឲ្យយោបល់ផ្ទាល់ខ្លួន ចំពោះទស្សនៈនេះ ។

៨– កំសត់ក្នុងរឿងក្រុងសុកមិត្រ

(មធ្យមសិក្សាប័ត្រ ឆ្នាំ ១៩៥៩)

៩- នាងកេសរីមានទុក្ខដោយសារកម្មផលក្នុងអតីតកាល នាងកាកីមានទុក្ខដោយបុព្វហេតុក្នុងបច្ចុប្បន្នកាល ។ តើការប្រៀបធៀបដោយគូអង្គទាំងពីរនេះ អាចបង្ហាញនូវសារសំខាន់ក្នុងអក្សរសិល្ប៍ខ្មែរឬទេ ?

១០- ការព្រាត់ប្រាស់នៅក្នុងរឿងក្រុងសុភមិត្រ ។

១១- តើការចោទប្រកាន់របស់នាយកេត្រា ចំពោះកុមារជ័យសែននឹងជ័យទត្តថា ស្រឡាញ់ប្រពន្ធនាយកេត្រា ដែលជាម្តាយឯងនោះ (នាងកេសរី) សមហេតុសមផលដែរឬទេ ?

សូមដោះស្រាយនិងពិភាក្សាឲ្យយោបល់

សូម.លោកអ្នកនាងរង់ចាំ :

# អត្ថបទវិជ្ជា រឿង - គោតកុលកុមារ

# - កាកី - ភមកើរ្ត

របស់អ្នកនិពន្ធ អុំ - មារឌី

នឹងចេញផ្សាយនៅពេលឆាប់ ៗ នេះ.ហើយ

ដោយ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

## បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

ដែលធ្លាប់ទទួលអស់លោក-អ្នក-នាងដោយរាក់ទាក់នោះ សូមជំរាបជូនជាថ្មីថា ៖ ទីនេះសម្រាំងយកសៀវភៅសិក្សាបារាំង-ខ្មែរល្អៗ ទុកជូនលោក-អ្នក-នាងឲ្យបានពេញចិត្ត ។

បណ្ណាគារខ្ញុំ មានប្រដាប់ប្រដាសរសេរ-គ្រឿងសម្ភារៈការិយាល័យ - ទស្សនាវដ្តីខ្មែរ-បារាំងសម្រាប់យុវជន ទីន ប្រហោមលោកគ្រប់មុខ ។

សូមកុំភ្លេច អញ្ជើញទាក់ទងតាមត្រូវការ ។

**បណ្ណាគារ ពន្លឺអក្សរសាស្ត្រ**

**១៣៨ វិថីព្រះបាទសីហនុ ភ្នំពេញ**

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨-វិថីព្រះបាទសីហនុ ភ្នំពេញ

ព្រលឹងខ្មែរ

បោះពុម្ពហួរ-មួយ

តម្លៃ ១៨រៀល